លំហាត់ ៨ និង ៩ ............................................................៧៨
លំហាត់ ១០ ................................................................... ៨៥
លំហាត់ ១១ ...................................................................៨៧

مدرسة اهل البيت

# សាលា អាស់លុល-បៃត៍

## សៀវភៅ ហ្វីកោះហ៍ ថ្នាក់ទី ៨

(អាយុ ១២-១៣ ឆ្នាំ)

រ៉សូលុលឡោះហ៍ﷺមានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជា ជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - ស្ហ៏ឡាត្ហ់ - ស្ហ៏ឡាត្ហ់ យ៉ាំម៉ាអ៊ុស្ហ់(១) ............៥
មេរៀនទី ២ - ស្ហ៏ឡាត្ហ់ - ស្ហ៏ឡាត្ហ់ យ៉ាំម៉ាអ៊ុស្ហ់(២)......... ១០
មេរៀនទី ៣ - ណាយ៉ាំសាស្ហ់.................................... ១៧
មេរៀនទី ៤ - គ៊ុសល៍ (ឬ គ៊ុស៊្ហូល غسل) .........................២១
មេរៀនទី ៥ - បែបបទក្នុងការបន្ទោបង់ ........................២៥
មេរៀនទី ៦ - មូតោះហ្វ៊ីរ៉ត់(១)......................................២៨
មេរៀនទី ៧ - មូតោះហ្វ៊ីរ៉ត់(២)....................................៣៣
មេរៀនទី ៨ - ស្ហ៏ឡាត្ហ់ យ៉ុមអ៊ុត្ហ់ (ស្ហ៏ឡាត្ហ់ ថ្ងៃសុក្រ)..... ៣៨
មេរៀនទី ៩ - ស្ហ៏ឡាទ្ហុល អ៊ីដ្វៃន៍ (ស្ហ៏ឡាត្ហ់ អ៊ីដ្វទាំងពីរ). ៤៣
មេរៀនទី ១០ - ស្ហ៊ីហ្វាត់ ស្ហ៊ុប៊ូទីយ៉ាស្ហ់ (الصفات الثبوتية)..... ៤៧
មេរៀនទី ១១ - ម៉ាសាអ៊ីល(مسائل) យ៉ាំប៊ីរ៉ោះត្ហ៍ (جبيرة)......៥២
មេរៀនទី ១២ - ពាក្យបច្ចេកទេសអ៊ីស្លាម .....................៥៨
មេរៀនទី ១៣ - អាស្ហ់កាមុល អ៊ីសទីបរ៉អ៍ (احكام الاستبراء).៦២
លំហាត់ ១...............................................................៦៥
លំហាត់ ២...............................................................៦៦
លំហាត់ ៣ ............................................................. ៦៧
លំហាត់ ៤.............................................................. ៧០
លំហាត់ ៦.............................................................. ៧៤
លំហាត់ ៧ ............................................................. ៧៦

បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៣ នាក់ រ៉ក់អាត់នីមួយៗស្មើ ៦០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៤ នាក់ រ៉ក់អាត់នីមួយៗស្មើ ១២០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៥ នាក់ រ៉ក់អាត់នីមួយៗស្មើ ២៤០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៦ នាក់ រ៉ក់អាត់នីមួយៗស្មើ ៤៨០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៧ នាក់ រ៉ក់អាត់នីមួយៗស្មើ ៩៦០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៨ នាក់ រ៉ក់អាត់នីមួយៗស្មើ ១៩២០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៩ នាក់ រ៉ក់អាត់នីមួយៗស្មើ ៣៦៤០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ១០ នាក់ រ៉ក់អាត់នីមួយៗស្មើ ៧២៨០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នាលើសពី ១០ នាក់ រ៉ក់អាត់នីមួយៗមិនអាចកាត់ថ្លៃបានទេ មានតែអល់ឡោះហ្វទេដែលអាចរាប់អស់ ។

មិនបាច់ចងចាំអ្វីដែលនៅខាងលើនេះទេ គ្រាន់តែចង់ឲ្យដឹង



**មេរៀនទី ១**

# ស្វ៍ឡាត់ - ស្វ៍ឡាត់យ៉ាម៉ាអាស់

(صلاة الجماعة)

**ផលប្រយោជន៍ផ្លូវធម៌និងផ្លូវសម្ភារៈ**

ស្វ៍ឡាត់យ៉ាម៉ាអាស់មានន័យថា បំពេញនមស្ការជុំគ្នា ។ មគ្គផលច្រើនណាស់ ពេលណាស្វ៍ឡាត់ត្រូវបំពេញជាស្វ៍ឡាត់យ៉ាម៉ាអាស់ ។ វាផ្តល់ឲ្យយើងនូវអត្ថប្រយោជន៍ផ្លូវធម៌ក៏ដូចផ្លូវសម្ភារៈដែរ ។

**១-ភាពស្មើគ្នាក្នុងសាសនាអ៊ីស្លាម**

ការប្រជុំគ្នា អ្នកមាននិងក្រ ខ្ពស់ទាប ទាំងអស់គ្នាក្រោកឈរស្មាទល់ស្មា ។ ជាទិដ្ឋភាពប្រសើរបំផុតដែលឆ្លុះបញ្ចាំងនូវភាពស្មើគ្នានៃមនុស្ស ។

**២-ឯកភាព**

ក្នុងស្វ៍ឡាត់នេះ ទាំងអស់គ្នាមាននៀតតែមួយ ភាសាតែមួយ ទង្វើតែមួយ ។ បង្អោនកាយជាមួយគ្នា ក្រាបប្រណិប័តន៍ជាមួយគ្នា ។ នេះជាមេរៀនមួយរបស់យើងគឺៈ ជាមុស្លីម យើងត្រូវឯកភាពគ្នាគ្រប់ពេល ។

### ៣-សេចក្តីស្រឡាញ់និងសហប្រតិបត្តិការ

មនុស្សជួបគ្នាក្នុងពេលស្វ៍ឡាត់យ៉ាម៉ាអ្ហុស្វ៎ ។ គេឲ្យដំណឹងគ្នាទៅវិញទៅមក អំពីសេចក្តីលំបាកនិងសេចក្តីបារម្ភ ហើយព្យាយាមជួយគ្នាទៅវិញទៅមក ។ គេទទួលបាននូវព័ត៌មានថ្មីៗក្នុងពេលស្វ៍ឡាត់យ៉ាម៉ាអ្ហុស្វ៎ ។ សេចក្តីស្រឡាញ់គ្នាទៅវិញទៅមករីកចម្រើនឡើង នៅក្នុងពេលស្វ៍ឡាត់យ៉ាម៉ាអ្ហុស្វ៎ ។ រង្វង់មិត្តភាពកាន់តែវាតទំហំនៅពេលនោះ ។ នៅពេលនោះយើងអាចមានឱកាសអាចធ្វើឲ្យជីវិតយើងកាន់តែប្រសើរឡើង ដោយអាស្រ័យលើបទពិសោធន៍របស់អ្នកឯទៀត ។

### ៤-វិន័យ



ពេលយើងស្វ៍ឡាត់យ៉ាម៉ាអ្ហុស្វ៎ យើងតម្រង់ជួរតាមអ៊ីម៉ាំយ៉ាម៉ាអ្ហុស្វ៎ និងគោរពបូជាអល់ឡោះហ៍ ។ វាធ្វើឲ្យមានការគោរពវិន័យដែលជាកត្តាចាំបាច់ក្នុងជីវភាពសហគមន៍ ។

### ៥-កិត្យានុភាពរបស់អ៊ីស្លាម

ម៉ាស់យ៉ីដ្ធយើងរុងរឿងដោយសារស្វ៍ឡាត់យ៉ាម៉ាអ្ហុស្វ៎ ធ្វើឲ្យកិត្យានុភាពមុស្លីមកាន់តែមានឡើង ឯកភាពមុស្លីមធ្វើឲ្យសត្រូវញញើត ។

### ៦-រង្វាន់ឥតព្រំដែន

អល់ឡោះហ៍បានដាក់រង្វាន់យ៉ាងធំ សម្រាប់ស្វ៍ឡាត់យ៉ាម៉ាអ្ហុស្វ៎ ។ ព្រះសាស្តាﷺយើងនិងព្រះសន្តអ៊ីម៉ាំعليهم السلام មានព្រះវចនៈអន្ទោកអន្ទោល អំពីស្វ៍ឡាត់យ៉ាម៉ាអ្ហុស្វ៎ ។ ដូច្នេះយើងគប្បីបំពេញស្វ៍ឡាត់យ៉ាម៉ាអ្ហុស្វ៎ ឲ្យបានញឹកញយតាមដែលអាចធ្វើទៅបាន ។

បើស្វ៍ឡាត់យ៉ាម៉ាអ្ហុស្វ៎មានគ្នា ២ នាក់ រ៉ក់អ្ហាត់នីមួយៗស្មើ ៥០ ស្វ៍ឡាត់ ។

៨. ថែមរ៉ូកុនដោយចេតនាក្តី ដោយអចេតនាក្តី ធ្វើឲ្យស្ម៏ឡាត់មោឃៈ តែសម្រាប់ស្ម៏ឡាត់យ៉ាម៉ាអ៊ុស្វ ការបន្ថែមបែបនេះ ត្រូវអនុលោមដោយសារតែស្ម៏ឡាត់នេះសំខាន់ពេក (នឹងអធិប្បាយលំអិតនៅខាងមុខ) ។

## គ-ចូលរួមក្នុងស្ម៏ឡាត់យ៉ាម៉ាអ៊ុស្វដូចម្តេច

១. នៅក្នុងរ៉ក់អ៊ាត់ទី ១ និង ទី ២ របស់ស្ម៏ឡាត់យ៉ាម៉ាអ៊ុស្វ យកល្អឲ្យចូលរួមក្នុង ពេលដែលអ៊ីម៉ាំកំពុងតែសូត្រស៊ូរ៉ោះត៍ទីមួយ ឬស៊ូរ៉ោះត៍ទីពីរ ឬកំពុងតែរ៉ូគុអ៊ុ ។

២. នៅក្នុងរ៉ក់អ៊ាត់ទី ៣ និង ទី ៤ របស់ស្ម៏ឡាត់យ៉ាម៉ាអ៊ុស្វ យកល្អឲ្យចូលរួមក្នុង ពេលដែលអ៊ីម៉ាំចុះរ៉ូគុអ៊ុ ។ បើអ្នកចូលរួមក្នុងពេលគ្មីយ៉ាម ក្នុងពេលដែលអ៊ីម៉ាំកំពុងតែសូត្រស្ងាត់ៗ "តាស់ប៊ីហ្វាត់ អារបាអ៊ុស្វ" អ្នកចាំបាច់ត្រូវសូត្រយ៉ាងហោចណាស់ស៊ូរ៉ោះត៍អាល់-ហ្វាំដ៏ ហើយ បើអ្នកមិនអាចសូត្រស៊ូរ៉ោះត៍អាល់-ហ្វាំដ៏ចប់ទេ ហើយអ៊ីម៉ាំងើបឡើងពីរុគុអ៊ុវិញ អ្នកចាំបាច់ត្រូវប្តូរនៀតជាស្ម៏ឡាត់ហ្វ៊ូរ៉ដាវិញ ហើយបំពេញស្ម៏ឡាត់ឲ្យគ្រប់ជាស្ម៏ឡាត់ហ្វ៊ូរ៉ដា ។



ថាស្ម៏ឡាត់យ៉ាម៉ាអ៊ុស្វ និងស្ម៏ឡាត់ម្នាក់ឯងខុសគ្នាប៉ុណ្ណា ។ គេឃើញហើយថាបើមានគ្នាលើសពី ១០ នាក់ក្នុងស្ម៏ឡាត់យ៉ាម៉ាអ៊ុស្វ រង្វាន់របស់រ៉ក់អ៊ាត់នីមួយៗមិនមានអ្នកណាអាចកាត់ថ្លៃបានទេ ក្រៅពីអល់ឡោះហ្វ៍ ។

## ពាក្យបច្ចេកទេស

**អ៊ីម៉ាំ**=អ្នកនាំមុខស្ម៏ឡាត់ ។
**ម៉ាក់មុម** (مأموم)=អ្នកស្ម៏ឡាត់ខាងក្រោយអីម៉ាំ ។
**ហ្វ៊ូរ៉ដា** (فردى)=ស្ម៏ឡាត់តែឯង ។

## មេរៀនទី ២

# ស្វ៏ឡាត្វ៉ - ស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉(២)

### ខ-សារសំខាន់របស់ស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉

គេអាចយល់សារសំខាន់របស់ស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉បាន ដូចតទៅ គឺៈ

១. ដូចដែលបានអធិប្បាយខាងលើរួចមកហើយ រង្វាន់របស់ស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉គ្មានព្រំដែនទេ ។

២. ប្រសើរឲ្យចាំបន្តិចដើម្បីចូលរួម ក្នុងស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉ ជាជាងស្វ៏ឡាត្វ៉ម្នាក់ឯងនៅដើមពេល (អាវ៉ាល់ វ៉ាក់ទូ) ។

៣. បើអ្នកបានស្វ៏ឡាត្វ៉វ៉ាយ៉ីបហ្វ៍រ៉ដូរួចហើយ ហើយបានឃើញគេស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉ អ្នកនោះអាចមកចូលរួមក្នុងស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉បាន ហើយបំពេញស្វ៏ឡាត្វ៉ដដែលសាថ្មីបាន ។ អ្នកនោះនឹងទទួលបាននូវរង្វាន់ច្រើនដោយធ្វើបែបនេះ ។



៤. បើឪពុកនិងម្ដាយ ដាក់បញ្ជាឲ្យកូនប្រុសខ្លួនបំពេញស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉ បើកូនប្រុសនោះខ្លាចឪពុកម្ដាយទាស់ចិត្តបើខ្លួនមិនធ្វើតាមទេនោះ វ៉ាយ៉ីបសម្រាប់កូនប្រុសនោះត្រូវបំពេញស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉ ។

៥. អ្នកណាដែលមិនចេះថាឬសូត្រត្រឹមត្រូវទេ អ្នកនោះគប្បីបំពេញស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉ ដើម្បីសិក្សារបៀបសូត្រឲ្យបានត្រឹមត្រូវ ។

៦. យោលតាអ្នកប្រាជ្ញាមួយចំនួនខាងសាសនា គេមិនអាចបំពេញស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉ហ្វ៍រ៉ដូបានទេ ពេលដែលគេកំពុងបំពេញស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉ ។

៧. បើគេមិនអាចចាត់ទុកអ៊ីម៉ាំជា "អុាឌិល (គឺត្រឹមត្រូវ)" បានទេ ហើយបានចូលមកក្នុងម៉ាស់យ៉ីដហើយ គេត្រូវបំពេញស្វ៏ឡាត្វ៉ហ្វ៍រ៉ដូក្នុងចន្លោះអាស្វាន និងអ៊ីកូ៏ម៉ាត្វ៉ ឬត្រូវរង់ចាំឲ្យស្វ៏ឡាត្វ៉យ៉ាំម៉ាអុាស្វ៉ចប់ ជាការគោរព ហើយទើបបំពេញស្វ៏ឡាត្វ៉ហ្វ៍រ៉ដូ ។

៨. អ៊ីមុាំយ៉ាម៉ាអាស់មានលក្ខខណ្ឌដូចតទៅ គឺ៖

ក. បាលីក្ហ (គឺគ្រប់អាយុ) ។
ខ. អាចសូត្របានយ៉ាងត្រឹមត្រូវ (ម៉ាក្ហរីច្ចត្រឹមត្រូវ) ។
គ. ជាមុមីន - គឺ ស្ហ៊ីអាស់ អ៊ីស្នាអាស្ហារីយ៉ាស់ (شيعة اثنا عشرية)
ឃ. អាគ៊ីល (មានសតិអារម្មណ៍គ្រប់គ្រាន់ - មិនវិកលចរិត)
ង. មានកំណើតស្របច្បាប់ ។
ច. អាឌ៊ីល (គឺត្រឹមត្រូវ - យុត្តិធម៌) ។ អ្នកដែលគេមិនស្គាល់ថាជាបុគ្គលដែលប្រព្រឹត្តបាបធំ ដែលមានចរិយាមារយាទស្របតាមច្បាប់អ៊ីស្លាម ។



៣. បើអ្នកចូលមកក្នុងម៉ាស់យ៉ីដ្ហ ហើយមិនដឹងថាគេកំពុងតែបំពេញរ៉ក់អាត់ណាទេ អ្នកត្រូវរង់ចាំទាល់តែអ៊ីមុាំចុះទៅរ្កុអ៊ ។

៤. បើអ្នកចូលមកក្នុងម៉ាស់យ៉ីដ្ហ ហើយដឹងថាគេកំពុងតែស៊ូយ៉ូដ្ហរ៉ក់អាត់ចុងក្រោយ ហើយអ្នកចង់ចូលរួមក្នុងស្ហ៊ឡាត់យ៉ាម៉ាអាស់ដើម្បីទទួលបាននូវស្ហាវ៉ាប់ អ្នកត្រូវនៀត ហើយតាក់ប៊ីរ៉ទុល អ៊ិះហ្ររ៉ម ហើយចូលរួមក្នុងស្ហ៊ឡាត់យ៉ាម៉ាអាស់ត្រង់ស៊ូយ៉ូដ្ហ ។ បន្ទាប់មក ពេលអ៊ីមុាំតាស្ហាស់ហ៊្ហុដចប់ហើយឲ្យសាឡាមចប់ហើយ អ្នកត្រូវងើបឡើងវិញ ចាប់ផ្តើមសូត្រស៊ូរ៉ោះត៍ទីមួយនិងស៊ូរ៉ោះត៍ទីពីរ ។

ក) ក្នុងករណីនេះ ក្នុងពេលតាស្ហាស់ហ៊្ហុដនិងសាឡាម អ្នកត្រូវលើកជង្គង់ពីដី ច្រត់ដៃលើដី ចាំឲ្យអ៊ីមុាំសូត្រសាឡាមចប់ ។

ខ) បើអ្នកចូលរួមត្រង់រ៉ក់អាត់ទី២ ទី៣ ឬ ទី៤ ត្រូវលើកជង្គង់ក្នុងពេលតាស្ហាស់ហ៊្ហុដនិងសាឡាមដែរ ។

៥. ម៉ាក់មូមីន (ពួកម៉ាក់មុម) ដែលស្ហ៊ឡាត់នៅខាងក្រោយ

អ៊ីម៉ាំត្រូវសូត្រស៊ីកទាំងអស់ លើកលែងតែសូរ៉េះត៌ទី១និងសូរ៉េះត៌ទី២ក្នុងរ៉ក់អាត់ទី១និងទី២ ។

៦. អ្នកចាំបាច់ត្រូវសូត្រស្ងាត់ៗទាំងអស់ នូវអ្វីដែលត្រូវសូត្រ វ៉ាយ៉ីបឬស៊ូណាត់ តាមក្រោយអ៊ីម៉ាំ មិនឲ្យសូត្រមុនអ៊ីម៉ាំដោយចេតនាទេ ព្រោះវាធ្វើស្វ៍ឡាត់អ្នកមោឃ: ។

**ឃ-លក្ខខណ្ឌរបស់ស្វ៍ឡាត់យ៉ាម៉ាអាស់**

១. ជួរទីមួយ បន្ទាប់អ៊ីម៉ាំ ស៊ូណាត់ឲ្យមនុស្សចាស់និងអ្នកចេះដឹងនៅក្នុងជួរនេះ ។

២. អ្នកដំណើរដែលបំពេញស្វ៍ឡាត់ កូស្វ័រ (ស្វ៍ឡាត់អ្នកដំណើរ) ឬអ្នកដែលមានបញ្ហាដើរខ្យល់ មិនគប្បីនៅជួរទី១ទេ ។

៣. ត្រូវឈរក្នុងជួរជិតគ្នា ស្មាទល់ស្មា ។ ម៉ាក់រ៉ុះហ្វ៍បើចាប់ផ្តើមតម្រៀបជួរទី២នៅ ពេលដែលមាននៅសល់កន្លែងក្នុងជួរទី១ ។



៤. មានតែស្វ៍ឡាត់វ៉ាយ៉ីបទេ អាដាអ៍ ឬ ក៏ដ៏ ដែលអាចធ្វើបានជាស្វ៍ឡាត់យ៉ាម៉ាអាស់ ។ ស្វ៍ឡាត់ស៊ូណាត់មិនអាចធ្វើក្នុងស្វ៍ឡាត់យ៉ាម៉ាអាស់បានទេ លើកលែងតែស្វ៍ឡាទុលអ៊ីដ្វេន៍ (ស្វ៍ឡាត់អ៊ីដទាំងពីរ) និងស្វ៍ឡាត់អ៊ីសទីសក៏អ៍ ។

៥. ពេលអ៊ីម៉ាំសូត្រគាត់ប៊ីរ៉ទុល អ៊ិះហ៊្រាំម ប្រសើរឲ្យជួរទីពីរថាគាត់បៀរក្រោយជួរទីមួយ ។

៦. បើមានស្ត្រីចូលរួមក្នុងស្វ៍ឡាត់យ៉ាម៉ាអាស់ ត្រូវឲ្យនៅក្រោយប្រុសៗ (បើពុំមានរាំងនន)។ បើមានរាំងននរវាងប្រុសៗនិងស្រីៗ ស្រីៗអាចនៅស្មើប្រុសៗបាន ។

៧. អ៊ីម៉ាំយ៉ាម៉ាអាស់ប្រុសនិងអ៊ីម៉ាំយ៉ាម៉ាអាស់ស្រី ខុសគ្នាត្រង់ ៖

ក) អ៊ីម៉ាំប្រុសអាចមានម៉ាក់មូមីនប្រុសនិងស្រី ។ អ៊ីម៉ាំស្រីមិនអាចមានម៉ាក់មូមីនប្រុសបានទេ ។

ខ) អ៊ីម៉ាំប្រុសមានម៉ាក់មូមីន ឈរនៅខាងក្រោយ ។ អ៊ីម៉ាំស្រីឈរស្មើនឹងម៉ាក់មូមីនស្រីក្នុងជួរទីមួយ ។

មានជីវិត ដូចជា សក់ ក្រចក ឆ្អឹង ធ្មេញ ។ល។ មិនណាយ៉ីសទេ ។

**ឆ្កែនិងជ្រូក** ដែលរស់នៅលើផែនដីជាណាយ៉ីស ។ តាមន័យទូលាយ រោមវា ឆ្អឹងវា ធ្មេញវា និងញើសវា ជាណាយ៉ីស ។

**កាហ្វៀរ** កាហ្វៀរគឺបុគ្គលដែលមិនជឿអល់ឡោះហ្វ៍និងថ្ងៃជំនុំជម្រះទេ ។ មុស្សរីក (مشرك) គឺបុគ្គលដែលជឿថាអល់ឡោះហ្វ៍មានដៃគូច្រើន ដូច្នេះបុគ្គលនេះត្រូវចាត់ទុក ជាណាយ៉ីសដូចបុគ្គលកាហ្វៀរដែរ ។ ពួក "អាស្ល់លី គីតាប (اهل كتاب)" ដែលបដិសេធព្រះសាស្តា មូហាំម៉ាដ្ទ មុសតាហ្វាﷺ ជាណាយ៉ីសដែរ ។ រូបកាយមនុស្សបែបនេះជាណាយ៉ីស រាប់បញ្ចូលសក់ ក្រចក ធ្មេញនិងញើសពួកគេនោះផងដែរ ។

**ស្រា** : ភេសជ្ជៈស្រវឹងនេះជាណាយ៉ីស ។
**ហ្វ៊ុក្កក៏** : នេះគឺស្រាបឺយ៉ែរ ជាណាយ៉ីស ។



**មេរៀនទី ៣**

# ណាយ៉ាសាស្ស៎

**ណាយ៉ីស** គឺវត្ថុដែលត្រូវចាត់ទុកថាមិនស្អាតយោលតាមច្បាប់សាសនា(ស្សារីអ៊ាស្ស៎) ។

វត្ថុទាំងនេះមិនស្អាតដោយខ្លួនឯង ហើយធ្វើឲ្យវត្ថុផ្សេងមិនស្អាតដោយការប៉ះពាល់វា ។ វត្ថុមួយទៅជាណាយ៉ីស (គឺមិនស្អាត) ដោយការប៉ះពាល់ជាមួយណាយ៉ាសាស្ស៎ (តួអង្គណាយ៉ីស) ប្រសិនបើវត្ថុណាមួយនៃវត្ថុទាំងពីរទទឹកឬសើម ។ ដូច្នេះវត្ថុណាយ៉ីសដែលស្ងួតមិនអាចធ្វើឲ្យវត្ថុផ្សេងទៅជាណាយ៉ីសបានទេ បើវត្ថុមួយនេះស្ងួតដែរ ។

មានណាយ៉ាសាស្ស៎ពីរប្រភេទ វិធីជម្រះឲ្យបរិសុទ្ធពីណាយ៉ាសាស្ស៎នេះពឹងពាក់ទៅ លើប្រភេទរបស់ណាយ៉ាសាស្ស៎នេះ ។

ក) **ហាដាស្ស៎** (الحدث) គឺណាយ៉ាសាស្ស៎ដែលទាមទារឲ្យមាន

នៀត(បំណង)ដើម្បីជម្រះឲ្យបរិសុទ្ធ ។ នោះគឺណាយ៉ាសាស្ង់ ដែលគេជម្រះចេញតាមរយៈវូឌុអ៊ុ (وضوء) ឬ ក៊ុសល៍ (ឬ គ៊ុស្សូល غسل) ។

ហ្ាដាស្ង់មានពីរប្រភេទគឺៈ

១-(ហ្ាដាស្ង់ធំ) ចាំបាច់ត្រូវប្រើវិធីក៊ុសល៍ (ឬ គ៊ុស្សូល) ដើម្បីធ្វើឲ្យបរិសុទ្ធស្រប តាមច្បាប់សាសនា ។
២-(ហ្ាដាស្ង់តូច) ចាំបាច់ត្រូវប្រើវិធីវូឌុអ៊ុដើម្បីធ្វើឲ្យបរិសុទ្ធស្របតាមច្បាប់សាសនា ឧទាហរណ៍ ដេកលក់ជាដើម ។

ខ) **ខាបាស្ង់** ណាយ៉ាសាស្ង់ទាំងនេះមិនចាំបាច់ឲ្យមាននៀតទេ ដើម្បីធ្វើឲ្យបរិសុទ្ធស្របតាមច្បាប់សាសនា ។ ណាយ៉ាសាស្ង់ទាំងនេះមានចំនួន ១០ គឺៈ

| | | |
|---|---|---|
| ១. ទឹកនោម | ២. លាមក | ៣. ឈាម |
| ៤. ទឹកកាម | ៥. សាកសព | ៦. ឆ្កែ |
| ៧. ជ្រូក | ៨. កាហ្វៀរ | ៩. ស្រា |
| ១០. ហ្វ៊ុក្វក៏ | | |



**ទឹកនោមនិងលាមក** សត្វរស់ដែលឈាមបាញ់ (ពេលសំឡែះ) ហើយសាច់ហ្ារ៉ាំបរិភោគ ។ ក៏ប៉ុន្តែសត្វដែលសាច់ហ្ាឡាល់ទៅជាហ្ារ៉ាំបើវាស៊ីសំរាម ដូច្នេះទឹកនោមនិងលាមកវាទៅជាណាយ៉ីស ។ ឧទាហរណ៍ បើគោធ្លាប់តែស៊ីសំរាមមនុស្ស ទឹកនោមនិងលាមកវាទៅជាណាយ៉ីស ។ បានសេចក្តីថា បើអ្នកចង់ដឹងថាតើទឹកនោម និង/ឬ លាមកណាយ៉ីសឬទេ អ្នកត្រូវពឹងផ្អែកលើសំណួរពីរខាងក្រោមនេះគឺៈ

១-តើឈាមសត្វនោះចេញមកដោយបាញ់ទេ ?
២-តើសាច់សត្វនោះហ្ារ៉ាំទេ ?

**ឈាម** សត្វដែលឈាមបាញ់ (ពេលសំឡែះ) ទោះបីសាច់វាហ្ាឡាល់ឬមិនហ្ាឡាល់ក៏ដោយ ។

**សាកសព** របស់សត្វទាំងឡាយណាដែលឈាមបាញ់ ។ ក៏ប៉ុន្តែសាកសពសត្វ ដែលសាច់ហ្ាឡាល់ហើយត្រូវសំឡែះស្របតាមច្បាប់សាសនានោះ ជាសាកសពបរិសុទ្ធ ។ សាកសពមុស្លីម ក្រោយពីបានលាងសម្អាតស្របតាមច្បាប់សាសនាហើយ ទៅជាបរិសុទ្ធ ។ ប៉ែកនៃរូបកាយដែលមិន

ដំបូងប៉ែកខាងស្តាំទាំងអស់របស់ខ្លួន រាប់បញ្ចូលខ្នាស បន្ទាប់មកលាងប៉ែកខាងឆ្វេងទាំងអស់របស់ខ្លួន (ខ្នាសដែរ) ។

២. **គុសល៍ អៀរទីម៉ាសុី** (غسل الارتماسى) គឺគុសល៍ដែលធ្វើតែមួយលើក ដោយមុជក្នុងទឹក ។ អាចប្រព្រឹត្តទៅបានក្នុងទន្លេ ក្នុងស្ទឹង ក្នុងអាងហែលទឹក ឬក្នុងអាងទឹកធំលើសពីមួយ "គូរ" ។ ក្រោយពីនៀតរួច មុជក្នុងទឹកទាំងខ្លួនតែម្តង ។



**មេរៀនទី ៤**

# គុសល៍ (ឬ គុស៊ូល)

គុសល៍ (ឬ គុស៊ូល غسل) ជាពាក្យអារ៉ាប់ មានន័យថា "ងូតទឹកដើម្បីលាងបន្សុទ្ធខ្លួន" ។ ច្បាប់អុីស្លាម ស្ហារីអុាស់ (شريعة) បានដាក់គុសល៍ជាបង្គាប់វ៉ាយ៉ីប សម្រាប់ស្ថានភាពមួយចំនួន ជាស៊ូណាត់សម្រាប់ស្ថានភាពមួយឯទៀត ។ ក្នុងករណីគុសល៍ ស៊ូណាត់ មានស្ហារ៉ាប់ច្រើន ។ របៀបប្រតិបត្តិគុសល៍មានចែងនៅក្នុងច្បាប់ស្ហារីអុាស់ ហើយមិនអាចធ្វើតាមរបៀបផ្សេង ពីរបៀបដែលច្បាប់ស្ហារីអុាស់បានចែងនោះជាដាច់ខាត ។

**ប្រភេទគុសល៍** បានអធិប្បាយខាងលើហើយ គុសល៍អាចជាវ៉ាយ៉ីប ឬ ជាស៊ូណាត់ ។

មាន ៧ គុសល៍វ៉ាយ៉ីប មានដូចជា គុសល៍ ម៉ាយិត, គុសល៍ ម៉ាស់ ម៉ាយិត, គុសល៍ ណាស្ស៍រ៍, គុសល៍ ក៏្វសុីម៉ា(قسم), គុសល៍ អាហ្វាដ្ឋ៍(عهد) ។ល ។

មានច្រើនគុ្ហសល់ ស៊ូណាត់្ហ។ គុ្ហសល់ ស៊ូណាត់្ហមួយ ក្នុងចំណោមគុ្ហសល់ ស៊ូណាត់្ហ ដែលសំខាន់បំផុតគឺ គុ្ហសល់ យុ្ជុមអា្ហត់្ហ(ថ្ងៃសុក្រ) ដែលម៉ាក្ហុស្សមីនយើង عليهم السلام បានផ្ដែផ្ដាំ ។ គុ្ហសល់ ស៊ូណាត់្ហមួយទៀតគឺ គុ្ហសល់ អុ្ហីដ្វ (ថ្ងៃបុណ្យ អុ្ហីឌ្វុល ហ្វីត្ហរ៍ (عيد الفطر) ឬ អុ្ហីឌ្វុល អាដ្ហ៍ហ្ហា (عيد الأضحى) ។

## លក្ខខណ្ឌរបស់គុ្ហសល់

ក) ទឹកកុ្ហសល់ត្រូវតែបរិសុទ្ធ មុត្ហឡាក្ហ(مطلق) និង មូបាស្ហ ។

ខ) កន្លែងដែលយកទឹកកុ្ហសល់ត្រូវតែមូបាស្ហ ។ សម្ភារៈប្រើសម្រាប់យកទឹកគុ្ហសល់ត្រូវមូបាស្ហដែរ មិនធ្វើអំពីមាសឬប្រាក់ទេ ។

គ) មុនយកទឹកគុ្ហសល់ រូបកាយរបស់អ្នកត្រូវស្អាតពីណាយ៉ីសគ្រប់ប្រភេទជាមុនសិន ដូចជា ទឹកកាម ឬ ឈាមរដូវខែ(حيض) ។

ឃ) គុ្ហសល់ត្រូវប្រតិបត្តិទៅក្នុងបំណង គុ្ហរបាតាន់



អុ្ហីឡុលឡោះហ្វ ពោលគឺ ក្នុងបំណងទៅរកអល់ឡោះហ្វ عزّ وجلّ និងក្នុងបំណងគោរពតាមព្រះបញ្ជាព្រះអង្គ عزّ وجلّ ។

ង) គុ្ហសល់ត្រូវប្រតិបត្តិដោយខ្លួនឯង មិនពឹងអ្នកដទៃទេ លើកលែងតែមានជម្ងឺ ។

ច) ការប្រើទឹកដើម្បីបំពេញគុ្ហសល់ មិនត្រូវធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពទេ ។

ឆ) ត្រូវយកចេញនូវសារធាតុខ្លាញ់ ឬ វត្ថុកខ្វក់ដទៃទៀត ដែលឃាត់ទឹកមិនឲ្យទៅដល់រូបកាយ ។ ដូច្នេះ ប្រេង ថ្នាំលាបសក់ឲ្យរឹង ថ្នាំលាបក្រចក ក្រមួនលាបបបូរមាត់ ។ល ។ ចាំបាច់ត្រូវយកវាចេញឲ្យអស់មុនយកទឹកគុ្ហសល់ ។

## របៀបយកទឹកគុ្ហសល់

**១. គុ្ហសល់ តារទីប៊ី** (الغسل الترتيبى) គឺគុ្ហសល់ដែលប្រព្រឹត្តទៅតាមលំដាប់ ។ បន្ទាប់ពីនៀតរួច លាងក្បាលរហូតដល់ក ។ បន្ទាប់មក ត្រូវលាងប៉ែករូបកាយដែលនៅសល់ ឬ លាង

**មេរៀនទី ៦**

# ម្វូតោះហ្ហ៊ីរ៉ត់(១)

មាន ១២ ម្វូតោះហ្ហ៊ីរ៉ត(مطهرات)ដែលធ្វើឲ្យវត្ថុត្រូវណាយ៉ើសបរិសុទ្ធស្អាតបាន គឺ៖

| | |
|---|---|
| ១. ទឹក | ២. ដី |
| ៣. ថ្ងៃ | ៤. អ៊ីសទីហ្ហាឡាស់(إستحالة) |
| ៥. អ៊ីនគ្វីឡាប់ | ៦. អ៊ីនទីក្វាល់(إنتقال) |
| ៧. អ៊ីស្លាម | ៨. តាបាអ៊ីយ៉ាស់(تبعية) |
| ៩. ស្ហាវ៉ាល់ អាល់-អ៊ៃន៍ | ១០. កុយ់បាត់ អាល់-មុស្លីម |
| ១១. អ៊ីសទីបរ៉អ៊ុ៍(استبراء) | ១២. សំណល់ឈាម ក្រោយពីសំឡេះ |

**១. ទឹក**

មានទឹក ២ ប្រភេទគឺ៖

ទឹកបរិសុទ្ធ(មុត្ថឡាក់ المطلق) - គឺទឹកដែលមិនបានផ្លាស់ប្តូរសោះ ទាំងព័ណ៌ ទាំងក្លិន និងទាំងរសជាតិ ។ ទឹកមុតឡាក់



**មេរៀនទី ៥**

# បែបបទក្នុងការបន្ទោបង់

**ច្បាប់បន្ទោបង់**

១. កន្លែងអង្គុយដើម្បីបត់ជើងតូច ឬ បត់ជើងធំចាំបាច់ត្រូវឲ្យខ្ទាសកំបាំង(ពីភ្នែកអ្នកដទៃ) ។

២. ឈានចូលក្នុងបង្គន់ដោយជើងឆ្វេង ហើយច្រត់លើជើងឆ្វេងដើម្បីអង្គុយ ។

៣. ហ្រាំបត់ជើងតូចឬបត់ជើងធំនៅកន្លែងដូចតទៅគឺ៖

-លើកន្លែងអ្នកដទៃ ដោយឥតបានទទួលការអនុញ្ញាតពីម្ចាស់កន្លែង ។

-លើកន្លែងដែលទុកសម្រាប់តែក្រុមណាមួយ (សម្រាប់បុគ្គលដែលមិនមែនជាសមាជិករបស់ក្រុមនេះ) ។

-លើផ្នូរមុស្លីម និងលើកន្លែងសក្ការបូជា (ម៉ាស់យ៉ិជ្ជ, អ៊ីម៉ាំបារ៉...)

៤. ហ្វ៉ាំបែរខ្នងឬបែរមុខដាក់គ៌្គីបឡាត់ពេលបត់ជើងតូច ឬបត់ជើងធំ ។

៥. ក្រោយពីបត់ជើងតូចរួចត្រូវលាងពីរដង (យកល្អបីដង) ។

៦. ក្រោយពីបានបត់ជើងធំរួចត្រូវលាងដោយទឹក ពុំនោះទេអាចជូតបានជាមួយក្រដាសស្អាត (ត៌្ហេវៀរ) ហើយស្ងួត ។ ត្រូវប្រើបីចំណែកក្រដាសដាច់ឡែកគ្នា ។ ប្រសើរឲ្យលាងជាមួយទឹក ក្រោយពីបានបត់ជើងធំរួចក៏ប៉ុន្តែអាចប្រើក្រដាសនិងទឹកបាន ។

៧. ហ្វ៉ាំប្រើវត្ថុជាទីសក្ការបូជាជូត (ឬកិត) ក្រោយពីបានបត់ជើងធំរួច ដូចជា "ខាកេ ស្ហីហ្វាអ៊្វ" (គឺដីការបាឡាអ៊្វ) ក្រដាសមានព្រះនាមអល់ឡោះហ្វ៍ﷻ ព្រះនាមម៉ាក់ស្ហុមមីនعليهم السلام ជាដើម ។

៨. និយាយនៅក្នុងបង្គន់ជាម៉ាក់រុះហ្វ៍ ។

៩. ហាមបត់ជើងតូចលើកន្លែងដូចតទៅ ដោយមាន



លក្ខខណ្ឌ គឺៈ

-ពេលឈរ (បត់ជើងតូចឈរមានទណ្ឌកម្មធ្ងន់ក្រោយពីស្លាប់) ។

-កន្លែងដែលខ្យាយប៉ះអ្នកដទៃ ។

-ក្នុង(ឬដាក់)ទឹក ។

-ដាក់រន្ធ(ឬរូង) (រន្ធក្នុងដីរបស់សត្វ) ។

-លើផ្លូវ ។

-ជិតជញ្ជាំងម៉ាស់យ៊ីដ្ឋ ។

-នៅទីបរិវេណផ្ទះ ។

-ក្រោមដើមឈើហូបផ្លែ ។

-កន្លែងដែលអាចធ្វើឲ្យមនុស្សទើសទាល់ចិត្ត ។

ទេនៅពេលដែលវាធ្វើឲ្យវត្ថុត្រូវណាយ្ជីសបរិសុទ្ធ ។ ដូច្នេះ ដើម្បីលាងជាមួយទឹក ចាំបាច់ត្រូវយកណាយ្ជីសចេញពីវត្ថុត្រូវណាយ្ជីសសិនដោយការលាង ។ ត្រូវពូតសំលៀកបំពាក់ក្រោយពីបោករួច ។



អាចធ្វើឲ្យវត្ថុត្រូវណាយ្ជីសទៅជាបរិសុទ្ធបាន ។

ទឹកលាយ ឬ ទឹកល្បាយ (مضاف) - ទឹកល្បាយមិនអាចធ្វើឲ្យវត្ថុត្រូវណាយ្ជីសទៅជាបរិសុទ្ធបានទេ ។ វាទៅជាណាយ្ជីសបើវាប៉ះណាយ្ជីស ។

ទឹកខាងក្រោមនេះជាទឹកមុត្ល្ទឡាក់ គឺះ

-ទឹកភ្លៀង ។

-ទឹកហូរ (រាប់បញ្ចូលទឹកម៉ាស៊ីនដែរ) ។

-ទឹកអណ្ដូង ។

-ទឹកនឹង (ទឹកក្នុងអាង, ធុង...) ដែលមានចំនួនលើសពីមួយ "គូរ" ។ (អាប់ កាស៊្សៀរ)

-ទឹកនឹង (ទឹកក្នុងអាង, ធុង...) ដែលមានចំនួនតិចជាងមួយ "គូរ" ។ (អាប់ ក៏្ទលីល)

ទឹកមួយ "គូរ" គឺទឹកក្នុងអាងឬធុងទំហំលើសពី ៣៨៤ លីត្រ (អាងទឹកបួនជ្រុងដែល មានប៉ែកខាងប្រវែង ៧២,៦៨ សង់ទីម៉ែត្រ ស្មើនឹង ៧ តឹក) ។

ទឹកតិចជាងមួយ "គូរ" ទៅជាណាយ្ជីសបើវាប៉ះណាយ្ជីស ។

## ការប្រើប្រាស់ទឹកក្នុងការជម្រះបន្សុទ្ធ

| វត្ថុត្រូវណាយ៉ីសដែលត្រូវជម្រះបន្សុទ្ធ | ជម្រះបន្សុទ្ធជាមួយទឹកដែលមានចំនួនលើសពីមួយ "គួរ" | ជម្រះបន្សុទ្ធជាមួយទឹកដែលមានចំនួនតិចជាងមួយ "គួរ" |
|---|---|---|
| សំលៀកបំពាក់ណាយ៉ីសដោយសារទឹកនោម | ១ ដង (យកល្អ ២ ដង) | ២ ដង (យកល្អ ៣ ដង) |
| សំលៀកបំពាក់ណាយ៉ីសដោយសារអ្វីផ្សេងពីទឹកនោម | ១ ដង | ២ ដង |
| ខ្លួនណាយ៉ីសដោយសារទឹកនោម | ១ ដង | ២ ដង |
| ខ្លួនណាយ៉ីសដោយសារអ្វីផ្សេងពីទឹកនោម | ១ ដង | ១ ដង |
| គ្រឿងប្រើប្រាស់សម្រាប់ផ្ទះបាយ | ១ ដង | ៣ ដង |



| | | |
|---|---|---|
| ត្រូវណាយ៉ីស | | |
| គ្រឿងប្រើប្រាស់សម្រាប់ផ្ទះបាយដែលត្រូវជ្រូកលិទ្ធ ឬ កណ្ដុរស្លាប់លើ | ៧ ដង | ៧ ដង |
| គ្រឿងប្រើប្រាស់សម្រាប់ផ្ទះបាយដែលណាយ៉ីសដោយសារស្រា | ៣ ដង | ៣ ដង |
| គ្រឿងប្រើប្រាស់សម្រាប់ផ្ទះបាយដែលត្រូវឆ្កែលិទ្ធ ឬ ទឹកមាត់ឆ្កែធ្លាក់លើ | ដុសជាមួយដីទទឹក ហើយ លាងទឹក ៣ ដង | ដុសជាមួយដីទទឹក ហើយ លាងទឹក ៣ ដង |
| គ្រឿងប្រើប្រាស់សម្រាប់ផ្ទះបាយដែលត្រូវឆ្កែលិទ្ធ ឬ ទឹកមាត់ឆ្កែធ្លាក់លើ | ដុសជាមួយដីទទឹក ហើយ លាងទឹក ៣ ដង | ដុសជាមួយដីទទឹក ហើយ លាងទឹក ៣ ដង |

លើសពីបរិសុទ្ធនិងមុត្ដឡាក្ក់ (គឺបរិសុទ្ធតាំងពីកំណើត) ទឹកមិនត្រូវឲ្យក្លាយទៅជាមូដ្ឆហ្វ់ (ប្ដូរភាពដោយការប៉ះពាល់)

ទៅជាបរិសុទ្ធដែរ ។

ង) គ្រែស្នែងម៉ាយិត ដែលធ្វើអំពីឈើឬស៊ីម៉ង់ត៍ដែលដាក់ម៉ាយិត ព្រមទាំងក្រណាត់សម្រាប់គ្របខ្មាស់ម៉ាយិត ទៅជាបរិសុទ្ធព្រមនឹងសាកសពដែលត្រូវផ្ងូតទឹកតុសល់ ម៉ាយិតឲ្យនោះដែរ ។

**៩. ស្វាល់ អាល់-អៃន៍ (យកណាយ៉ីសចេញ)**

បើមានណាយ៉ីសនៅលើខ្លួនសត្វ ខ្លួនសត្វនោះស្អាតវិញបើគេយកណាយ៉ីសនោះចេញ ។ មិនចាំបាច់លាងវាទេ ។ ដូចគ្នាដែរ បើមានឈាមនៅក្នុងមាត់ឬនៅលើច្រមុះ ហើយគេបានយកវាចេញ កន្លែងនោះទៅជាបរិសុទ្ធវិញ ។

**១០. កុយ់បាត់ អាល់-មុស្លីម (បាត់ខ្លួនមុស្លីម)**

បើអ្នកដឹងថាសំលៀកបំពាក់របស់មុស្លីមម្នាក់ ដែលស្របតាមច្បាប់ស្វារីអ៊ុស្ វ ទៅជាណាយ៉ីស បន្ទាប់មកមុស្លីមនេះបានកំបាំងពីភ្នែកអ្នកអស់រយៈពេលយូរបន្តិច ដែលគ្រប់គ្រាន់សម្រាប់ធ្វើឲ្យសំលៀកបំពាក់គេ ទៅជាបរិសុទ្ធបាន ។ ក្រោយមក អ្នកបានជួបគេម្តងទៀតជាមួយសំលៀកបំពាក់



**មេរៀនទី ៧**

# **មូតោះហ្ហ៊ីរ៉ត់**(២)

**២. ដី**

បើស្បែកជើងឬបាតជើងទៅជាណាយ៉ីស ដោយប៉ះណាយ៉ីសពេលដើរ វានឹងបរិសុទ្ធវិញបានដោយដើរមួយសន្ទុះលើដីស្អាតហើយស្ងួតទាល់តែណាយ៉ីសបាត់អស់ ។

**៣. ថ្ងៃ**

ថ្ងៃអាចធ្វើឲ្យវត្ថុទាំងនោះ ដែលគេមិនអាចប្តូរកន្លែងវាបានទៅជាបរិសុទ្ធវិញបាន ឧទាហរណ៍ ជញ្ជាំង ផ្លូវ ផ្ទៃដី ទ្វារ និងបង្អួច ។ល ។ ពេលណាយ៉ីសត្រូវយកចេញពីវត្ថុទាំងនេះ ហើយធ្វើឲ្យកន្លែងណាយ៉ីសទទឹក កាំរស្មីរបស់ថ្ងៃនឹងធ្វើឲ្យវត្ថុទាំងនេះបរិសុទ្ធ ។

**៤. អ៊ីសទីហ្វាឡាស់**(إستحالة ការផ្លាស់ប្តូរធាតុគីមី ឬ ធាតុអណ្វូ ឬម៉ូឡេគូល ពោលគឺ ប្រែរូប)

នេះគឺករណីដែលវត្ថុណាយ៉ីសផ្លាស់ប្តូរទាំងស្រុង ដល់ថ្នាក់

វត្ថុធាតុដើមរបស់វាបាត់អស់តែម្ដង ។ ឧទាហរណ៍ ដំបង ណាយ៉ីសឆេះទៅជាផេះ ឬឆ្កែងាប់រលួយហើយទៅជាធូលី ។

**៥. អ៊ីនគ៊ីឡាប់**

គឺការផ្លាស់ប្ដូរគុណភាពរបស់តួអង្គណាយ៉ីស (ខុសពីការផ្លាស់ប្ដូរវត្ថុធាតុដើម) ។ ឧទាហរណ៍ ពេលដែលស្រាទៅជាទឹកខ្មេះ ដោយសារការហួតចំហាយអស់ពីរភាគបីនៃចំនួនដើមរបស់វា ។

**៦. អ៊ីនទីកូល់**(إنتقال)

គឺការផ្លាស់ប្ដូរកន្លែងក្នុងករណីខ្លះ ។ ពេលតួអង្គណាយ៉ីសលាយជាមួយវត្ថុមួយទៀតដែលបរិសុទ្ធ វត្ថុនោះទៅជាបរិសុទ្ធ ។ ឧទាហរណ៍ មូសបឺតឈាមមនុស្ស (ដែលណាយ៉ីស) បន្ទាប់ពីមួយរយៈពេល ឈាមនេះទៅជាឈាមរបស់មូសនេះ ហើយឈាមមូសនេះបរិសុទ្ធ ។

**៧. អ៊ីស្លាម**

ពេលអ្នកឥតជំនឿមានសទ្ធាចំពោះអល់ឡោះហ្ 	عزّ وجلّ តែមួយគត់និងជឿព្រះសាស្ដាមូហាំម៉ាដ់ﷺ អ្នកនេះទៅជា



បរិសុទ្ធ ។

**៨. តាបាអ៊ីយ៉ាស់**(تبعية)

គឺករណីដែលវត្ថុណាយ៉ីសទៅបរិសុទ្ធតាមគ្នា (ឬដោយស្វ័យប្រវត្ត) ។ ឧទាហរណ៍៖

ក) ពេលបុគ្គលកាហ្វៀរទៅជាមុស្លីម បុគ្គលនោះទៅជាបរិសុទ្ធ ។ កូនៗរបស់អ្នកនោះ(ដែលមិនទាន់បាលិក គឺមិនគ្រប់អាយុ) ទៅជាបរិសុទ្ធជាស្វ័យប្រវត្ត ។

ខ) ពេលអណ្ដូងទឹកត្រូវណាយ៉ីស គេធ្វើឲ្យវាទៅជាបរិសុទ្ធវិញដោយយោងទឹកចេញមួយចំនួន ជញ្ជាំងអណ្ដូងទឹកនេះ ខ្សែវានិងធុងដែលគេប្រើសម្រាប់យោងទឹកទៅជាបរិសុទ្ធដែរជាស្វ័យប្រវត្ត ។

គ) ពេលគេលាងវត្ថុណាយ៉ីស ដំបូងដៃយើងទៅជាណាយ៉ីសដោយសារប៉ះពាល់ បន្ទាប់មកវាទៅជាបរិសុទ្ធព្រមគ្នានឹងវត្ថុដែលគេលាងដែរជាស្វ័យប្រវត្ត ។

ឃ) ពេលស្រាក្លាយទៅជាទឹកខ្មេះ ហើយទៅជាបរិសុទ្ធ របស់ដែលគេប្រើសម្រាប់ដាក់វា (គឺឆ្នាំង) នោះ

ស៊្ហរ៉ោះត៍្ហ ឬ អាយ៉ាត់្ហគួរអាន ។

៥. ដូចបានអធិប្បាយនៅខាងលើហើយ មិនមែនវ៉ាយ៊្ជីប ឲ្យបំពេញស្វ៏ឡាត់្ហថ្ងៃសុក្រ ដោយដាច់ខាតនោះទេ ។ គេអាចបំពេញស្វ៏ឡាត់្ហស្ហ៊ុស្ហរ៍ជួសបាន ។ តែបើអ៊ីមុាំអ្ហាឌីល (គឺអ៊ីមុាំត្រឹមត្រូវ) ដឹកនាំស្វ៏ឡាត់្ហថ្ងៃសុក្រ ជាអិះហ្ទ៍ទីយ៉ាត់្ហ វ៉ាយ៊្ជីប (إحتياط واجب) ចូលរួមក្នុងស្វ៏ឡាត់្ហនេះ ។

**អិះហ្ទ៍ទីយ៉ាត់្ហ វ៉ាយ៊្ជីប** មានន័យថា វ៉ាយ៊្ជីបបង្ការ ។ ដូចវ៉ាយ៊្ជីបដែរ តែខុសគ្នាត្រង់ដែលថា មុច្ជ៍តាហ្ទ៊ីដ្ហ (مجتهد អ្នកជំនាញខាងច្បាប់សាសនា) មួយចាត់ទុកថាជា "វ៉ាយ៊្ជីបបង្ការ" តែអនុញ្ញាតឲ្យតាមយោបល់របស់មុច្ជ៍តាហ្ទ៊ីដ្ហម្នាក់ទៀត ពាក់ព័ន្ធនឹងច្បាប់តែមួយ ។ ក្នុងករណីដែលអ្នកជ្រើសរើសយកយោបល់របស់មុច្ជ៍តាហ្ទ៊ីដ្ហម្នាក់ទៀត អ្នកត្រូវចាត់ទុកហ្វាត់វ៉ា (فتوى) របស់មុច្ជ៍តាហ្ទ៊ីដ្ហនេះជាវ៉ាយ៊្ជីប ហើយប្រតិបត្តិតាមហ្វាត់វ៉ានោះ ។

## របៀបស្វ៏ឡាត់្ហ

ស្វ៏ឡាត់្ហថ្ងៃសុក្រមានពីររ៉ក់អ្ហាត់្ហ ។ ក្នុងរ៉ក់អ្ហាត់្ហទីមួយ



ដដែល អ្នកត្រូវគិតថាគាត់បានធ្វើឲ្យសំលៀកបំពាក់គាត់បរិសុទ្ធហើយ ។

**១១. អ៊ីសទីបរ៉អ៊ុ៍** (استبراء **បង្ខាំង**)

សត្វហ្ទ៍ាឡាល់ ដូចជា គោ ចៀម មាន់ ទៅជាណាយ៊្ជីសបើវាស៊ីលាមកមនុស្ស ។ គេអាចធ្វើឲ្យវាទៅជាបរិសុទ្ធវិញបានដោយបង្ខាំងវាឆ្ងាយពីលាមកនោះ ហើយឲ្យវាស៊ីរបស់បរិសុទ្ធអស់មួយចំនួនថ្ងៃជាក់លាក់ ។ សម្រាប់គោ រយៈពេលគឺ ២០ ថ្ងៃ ។ សម្រាប់ចៀមគឺ ១០ ថ្ងៃ ។ សម្រាប់មាន់គឺ ៣ ថ្ងៃ ។

**១២. សំណល់ឈាមក្រោយពីសំឡេះ**

ពេលគេសំឡេះសត្វស្របតាមច្បាប់ស្ហារីអាស្ហ៍ ហើយឈាមវាបាញ់ចេញមកដោយមានចំនួនគ្រប់គ្រាន់ ឈាមដែលនៅសេសសល់ក្នុងខ្លួនវានោះជាឈាមបរិសុទ្ធ ។

**មេរៀនទី ៨**

# ស្វ៏ឡាត៌ ឃុ៊មអាត៌

## (ស្វ៏ឡាត៌ ថ្ងៃសុក្រ صلاة الجمعة)

ជាមួយអ៊ីម៉ាំصلوات الله عليه والسلام ឬ ជាមួយអ្នកតំណាងពិសេសរបស់ព្រះអង្គصلوات الله عليه والسلام ស្វ៏ឡាត៌ថ្ងៃសុក្រជា វ៉ាយ៊ីប អ៊ែនី (កាតព្វកិច្ចលើបុគ្គល) ជួសស្វ៏ឡាត៌ស្ហ៊ុស្វរ៍ ។ ក្នុងករណីនេះ គេមិនបំពេញស្វ៏ឡាត៌ស្ហ៊ុស្វរ៍ទេ ។

ក្នុងសម័យកាលកុ៎យ់បាស្វ៌របស់អ៊ីម៉ាំصلوات الله عليه والسلامយើង បើមិនមានអ្នកតំណាងពិសេសទេ ស្វ៏ឡាត៌ថ្ងៃសុត្រជា វ៉ាយ៊ីប តាឃ៊ីរី ។

អល់ឡោះហ្វ៍عز وجلមានព្រះបន្ទូលក្នុងស៊ូរ៉ោះត៍ ឃុ៊មអ៊ាត៌ (៦២:៩) ថា៖

*"អ្នកមានសទ្ធាទាំងឡាយអើយ ពេលគេហៅឲ្យធ្វើនមស្ការនាថ្ងៃសុក្រ ចូរពួកអ្នកប្រញាប់ឆ្ពោះទៅរកការរំលឹកដល់អល់ឡោះហ្វ៍ និងចូរទុកចោល[មួយអន្លើសិន]នូវកិច្ចការជួញដូរ ។ វាជាការប្រសើរបំផុតសម្រាប់ពួកអ្នក បើពួកអ្នក*



*ដឹង ។"*

**វ៉ាយ៊ីប តាឃ៊ីរី** មានន័យថា គេមានជម្រើសក្នុងពីរជម្រើស តែគេមិនអាចចោលទាំងពីរវ៉ាយ៊ីបបានទេ ។ ឧទាហរណ៍ ក្នុងរ៉ក់អ៊ាត៌ទី ៣ និងទី ៤ របស់ស្វ៏ឡាត៌ប្រចាំថ្ងៃ គេចាំបាច់ត្រូវសូត្រ ស៊ូរ៉ោះត៍ អាល់-ហ្វាំដ៍ ឬ សូត្រ "តាស់ប៊ីហ្វាត៌អារបាអ៊ាស្វ៌" តែគេមិនអាចសូត្រទាំងពីរបានទេ ។ ការសូត្រទាំងពីរនេះនៅក្នុងករណី វ៉ាយ៊ីប តាឃ៊ីរី ។

មានលក្ខខណ្ឌខ្លះក្នុងស្វ៏ឡាត៌ថ្ងៃសុក្រ គឺ៖

១. ស្វ៏ឡាត៌ថ្ងៃសុក្រចាំបាច់ប្រព្រឹត្តទៅជាយ៉ាម៉ាអ៊ាស្វ៌ ។
២. ត្រូវមាន ៥ នាក់ (យកល្អ ៧ នាក់) រាប់ទាំងអ៊ីម៉ាំផង ។
៣. ត្រូវធ្វើស្វ៏ឡាត៌ថ្ងៃសុក្រមួយក្នុងរង្វង់ ៥ គីឡូម៉ែត្រ ។ បើមានស្វ៏ឡាត៌ពីរនៅក្នុងរង្វង់នេះ ស្វ៏ឡាត៌ទីពីរត្រូវមោឃៈ ។
៤. អ៊ីម៉ាំត្រូវធ្វើឃុត្ពបាស្វ៌ពីរមុនស្វ៏ឡាត៌ ហើយត្រូវស្តាប់យ៉ាងយកចិត្តទុកដាក់ដោយមនុស្ស ៤ នាក់ (យកល្អ ៦ នាក់) ។ ឃុត្ពបាស្វ៌ទីមួយត្រូវស្តីអំពីភារកិច្ចធម្មតាភារកិច្ចរបស់មុស្លីមជាដើម ។ ឃុត្ពបាស្វ៌ទីពីរត្រូវស្តីអំពី

អ៊ីដ្វ អ៊ុល អាដ្ហា ប្រព្រឹត្តទៅក្នុងថ្ងៃដែលព្រះសាស្តា អ៊ីបរ៉ហ៊ីម عليه السلام មានបំណងធ្វើពលីកម្ម អ៊ីសម៉ាអ៊ីល រាជបុត្រ عليه السلام ព្រះអង្គ عليه السلام ដើម្បីគោរពតាមព្រះបញ្ជាអល់ឡោះហ្ عز وجل ។ គួរអានចែងរឿងរ៉ាវនេះដែលជាគំរូនៃការលះបង់ខ្លួនមួយដ៏មហិមា ។ បុណ្យអាដ្ហាជាការរំលឹកដល់ពលីកម្មនេះ ។ វាដាស់តឿនយើងឲ្យដឹងថាយើងត្រូវតែលះបង់កម្មសិទ្ធិយើងសព្វសារពើដែលយើងមាន រាប់បញ្ចូលជីវិតយើង និងជីវិតរបស់អ្នកជាទីស្រឡាញ់របស់យើងផងដែរ ដើម្បីមាគ៌ាអល់ឡោះហ្ عز وجل ប្រសិនបើចាំបាច់ត្រូវលះបង់នោះ ។ ក្នុងករណីនេះដែរ យើងថ្វាយអល់ឡោះហ្ عز وجل នូវស្វ៉ឡាត់ពិសេសមួយទៀតគឺ ស្វ៉ឡាត់ អ៊ីដ្វ ។

ស្វ៉ឡាត់ អ៊ីដ្វ ជាស៊ូណាត់ក្នុងកុយ់បាស៊ូរបស់អ៊ីម៉ាំ صلوات الله عليه والسلام យើង ។

## របៀបស្វ៉ឡាត់

នៀតគឺៈ ខ្ញុំបំពេញស្វ៉ឡាត់ស៊ូណាត់ អ៊ីដ្វ អ៊ុល-ហ្វីត្វរី (ឬ អ៊ីដ្វ អ៊ុល-អាដ្ហា) ពីររ៉ក់អាត់ គួរបាតាន់ អ៊ីលឡុលឡោះហ្ ។



ស៊ូណាត់ឲ្យសូត្រស៊ូរ៉ោះត៍ យ៉ុមអាត់ ក្រោយស៊ូរ៉ោះត៍អាល់-ហ្វាំដ៍ ។ ក្នុងរ៉ក់អាត់ទីពីរ សូត្រស៊ូរ៉ោះត៍ មូណាហ្វីគូន ក្រោយស៊ូរ៉ោះត៍ អាល់-ហ្វាំដ៍ ។

## គូទូត

ស៊ូណាត់ឲ្យសូត្រគូទូតពីរក្នុងស្វ៉ឡាត់នេះ ។ មុនរូគុអ៍ ក្នុងរ៉ក់អាត់ទីមួយ ក្រោយរូគុអ៍ ក្នុងរ៉ក់អាត់ទីពីរ ។ នេះគឺគូទូតសម្រាប់ស្វ៉ឡាត់ថ្ងៃសុក្រ ។

اَللّٰهُمَّ اِنَّ عَبِيْدًا مِّنْ عِبَادِكَ الصَّالِحِيْنَ قَامُوْا بِكِتَابِكَ

وَ سُنَّةِ نَبِيِّكَ فَاجْزِهِمْ عَنَّا خَيْرَ الْجَزَآءِ

អល់ឡហ៊ុមម៉ា អ៊ីនណា អាប៊ីដាំ មិន អ៊ីបាឌីកាស្វ ស្វ៉លីហ៊ីន ក៏មូ ប៊ីគីតាប៊ីកា វ៉ា ស៊ុនណាទី ណាប៊ីយីកា ហ្វាជ្ស៊ីហ៊ីម អាន់ណា ខយ់រ៉ល់ យ៉ាស្អ៍

អល់ឡោះហ្អើយ បាវបម្រើមួយចំនួនរបស់ព្រះអង្គដែលមានសទ្ធាស៊ប់ចិត្តមានគោលជំហរមាំមួន ដោយអាស្រ័យ

លើព្រះគម្ពីរព្រះអង្គ និងទំនៀមរបស់ព្រះសាស្តាព្រះអង្គ ។ ព្រះអង្គទ្រង់ព្រះរាជទានរង្វាន់ឲ្យពួកគេ ក្នុងចំណោមអស់ទូលព្រះបង្គំជាខ្ញុំយ៉ាងប្រសើរបំផុត ។



**មេរៀនទី ៩**

# ស្វឡាទុល អ៊ីដែន (ស្វឡាត់ អ៊ីដទាំងពីរ)

## (صَلَاةُ اَلْعِيدَيْنِ)

មុស្លីមកាន់បុណ្យធំពីររៀងរាល់ឆ្នាំ ។ បុណ្យទីមួយគឺ អ៊ីដ អ៊ុល-ហ្វិត្រី (عِيدُ اَلْفِطْرِ - ថ្ងៃទី ១ ខែ ស្សៅវ៉ាល់) បុណ្យទីពីរគឺ អ៊ីដ អ៊ុល អាដ្ហា (عيد الأضحى - ថ្ងៃទី ១០ ខែ ស្ទុល ហ្ហិច្ចយ៉ាស្ហ ذو الحجة) ។ ថ្ងៃទាំងពីរនេះជាបុណ្យធំ ។

អ៊ីដ អ៊ុល-ហ្វិត្រី ប្រព្រឹត្តទៅនៅថ្ងៃដាច់ខែរ៉ម៉ាដន ។ ការកាន់សីលត្រណមអាហារធ្វើ ឲ្យមានអារម្មណ៍សទ្ធាជ្រះថ្លា មានជំនឿ មានអំណត់ មានចិត្តសន្តោស និងមានអារម្មណ៍លះបង់ ។ សម្រាប់មុស្លីម បុណ្យមិនមានន័យថារាំរែក ឬច្រៀងទេ ។ យើងចុះចូលខ្លួនទាំងស្រុងចំពោះអល់ឡោះហ្វ៍ ដោយថ្វាយស្វឡាត់អ៊ីដចំពោះព្រះអង្គ ដែលយើងបានទទួលនូវអត្ថប្រយោជន៍ផ្លូវសាសនា ផ្លូវអារម្មណ៍សីលធម៌ក្នុងអំឡុងខែរ៉ម៉ាដន ។

**៤. ហៃ្យ** (الحي) មានន័យថាអល់ឡោះហ្វ៍ទ្រង់គង់នៅជានិច្ច ។

**៥. មូរីដ្ទ** (المريد) មានន័យថាអល់ឡោះហ្វ៍ទ្រង់មានមូលហេតុរបស់ព្រះអង្គផ្ទាល់ក្នុងកិច្ចការនីមួយៗ ។ ព្រះអង្គមិនធ្វើអ្វីមួយតាមតែក្បាលចិត្តឬដោយឥតគិតគូរនោះទេ ។

**៦. មុដ្ទរិក** (المودريك) មានន័យថាអល់ឡោះហ្វ៍ទ្រង់ទស្សនាការព្រះអង្គទ្រង់សវនាការ ដោយមិនចាំបាច់មានភ្នែកឬត្រចៀកទេ ។

**៧. មូតាកាល់លិម** (المتكلم) មានន័យថាអល់ឡោះហ្វ៍ជាព្រះម្ចាស់ពិភពលោក ។ ព្រះអង្គធ្វើឲ្យអ្វីមួយនិយាយបានស្រេចតែលើព្រះអង្គ ដូចដែលព្រះអង្គបានធ្វើឲ្យដើមឈើនិយាយបានជាមួយមូសាعليه السلام ហើយឲ្យ "វាំងននពន្លឺ" និយាយជាមួយព្រះសាស្ដាصلى الله عليه وآله وسلمបាន ។

**៨. ស្វ៏ឌិក្វ** (الصادق) មានន័យថាអល់ឡោះហ្វ៍មានសច្ចធម៌ក្នុងព្រះបន្ទូលនិងក្នុងពាក្យសន្យាព្រះអង្គ ។



រ៉ក់អ្ញាត់ទី ១ ស្វូណាត់ឲ្យសូត្រស្វូរ៉ោះត៏ អាល់-អាក់ឡា (៨៧) ក្រោយស្វូរ៉ោះត៏ អាល់-ហ្វាំដ៍ ។ បន្ទាប់មក សូត្រគុ្នូត ៥ ដងអមដោយតាក់បៀរ បន្ទាប់មកធ្វើរូគុអ៏និងស្វូយ៉ូដ ។

រ៉ក់អ្ញាត់ទី ២ ស្វូណាត់ឲ្យសូត្រស្វូរ៉ោះត៏ អាស្ស់-ស្វាំស៍ (៩១) ក្រោយស្វូរ៉ោះត៏ អាល់-ហ្វាំដ៍ ។ បន្ទាប់មក សូត្រគុ្នូត ៤ ដងអមដោយតាក់បៀរ បន្ទាប់មក ធ្វើរូគុអ៏ និង ស្វូយ៉ូដ ។

ដូច្នេះ រួមមាន ៩ គុ្នូត ។

នេះគឺឌូអ្ញាអ៏ គុ្នូត ៖

اَللّهُمَّ اَهلَ الْكِبْرِيَاءِ وَالْعَظَمَةِ، وَاَهْلَ الْجُوْدِ وَالْجَبَرُوتِ، وَاَهْلَ الْعَفْوِ وَالرَّحْمَةِ وَاَهْلَ التَّقْوٰى وَالْمَغْفِرَةِ، اَسْاَلُكَ بِحَقّ هٰذَا الْيَوْمِ الَّذِى جَعَلْتَه لِلْمُسْلِمِيْنَ عِيْدًا وَلِمُحَمَّدٍ صَلَّى اللهُ عَلَيْهِ وَآلِهِ ذُخْراً وَمَزِيْداً اَنْ تُصَلّيَ عَلٰى مُحَمَّدٍ وَآلِ مُحَمَّدٍ وَاَنْ تُدْخِلَنِى فِى كُلِّ خَيْرٍ اَدْخَلْتَ فِيْهِ مُحَمَّداً وَآلَ مُحَمَّدٍ، وَاَنْ تُخْرِجَنِى مِنْ كُلِّ سُوْٓءٍ اَخْرَجْتَ مِنْهُ مُحَمَّدًا وَآلَ مُحَمَّدٍ صَلَواتُكَ عَلَيْهِ وَعَلَيْهِمْ. اَللَّهُمَّ اِنّى اَسْاَ لُكَ خَيْرَمَا سَاَلَكَ عِبادُكَ الصَّالِحُونَ، وَاَعُوْذُ بِكَ مِمَّا اسْتَعاذَ مِنْهُ عِبادُكَ الصَّالِحُون

អល់ឡ៍ហ្វ៊ុមម៉ា អាស្ហ់ឡាល់ គីបរ៉អ៊ី វ៉ាល់អ៊ុស្ហ៍ម៉ាត្ហ់ វ៉ា អាស្ហ់ឡាល់យ៉្ហដ្ហ វ៉ាល់-យ៉្ហាបារូដ វ៉ា អាស្ហ់ឡាល់ អ៊ុហ្ហ់វី វ៉ារវ៉េះហ្វ៍ម៉ាស្ហ់ វ៉ា អាស្ហ់ឡាត់តាក្ហ់វ៉ា វ៉ាល់-ម៉ាក៊ុហ្វីវ៉េះត្ហ៍ អាស់-អាល្ហូកា ប៊ីហ្វាក្ហ់គ្ហី ហ្វាស្ហាល់-យ៉ៅមីល-ឡាស្ហ៊ី យ៉្ហាអ៊ុល់តាហ្វ៊ូ លិលមុស្លីមីណា អ៊ីដ្ហាន់ វ៉ាលីមូហ្វាំម៉ាឌ្ហីន ស្ហល់ឡល់ឡ៍ហ្វ៊ូ អ៊ុឡៃហ្វ៊ី វ៉ា អាលីហ្វ៊ី ស្ហ៊ុក៊ុវ៉ន់ វ៉ា ម៉ាស្ហ៊ីដ្ហាន់ អាន់ ទូស្ហល់លី-យ៉ាក៊ុឡា មូហ្វាំម៉ាដ្ហ់ វ៉ា អាលី មូហ្វាំម៉ាដ្ហ់ វ៉ា អាន់-ទុដ្ហយីឡានី ហ្វី គុល្លី ខយ់វីន អាដ្ហ់ខល់តា ហ្វីហ្វ៊ី មូហ្វាំម៉ាដ្ហាន់ វ៉ា អាឡា មូហ្វាំម៉ាដ្ហ់ វ៉ា អាន់-ទុក៊ុវីយ៉្ហានី មិន គុល្លី ស្ហូអ៊ុន អាក៊ុវ៉ច្ហ់តា មិនហ្វ៊ូ មូហ្វាំម៉ាដ្ហាន់ វ៉ា អាឡា មូហ្វាំម៉ាដ្ហ់ ស្ហ៍ឡាវ៉ាទូកា អ៊ុឡៃហ្វ៊ី វ៉ា អ៊ុឡៃហ្វ៊ីម ។

អល់ឡ៍ហ្វ៊ុមម៉ា អ៊ីននី អាស់អាល្ហូកា ខយ់វ៉ ម៉ា-អាស់អាឡាកា អ៊ីបាឌ្ហូកាស្ហ់-ស្ហ៍លីហ្វ៊ូន វ៉ា អាអ៊ុស្ហ៊ូប៊ីកា មីមម៉ាស់តាអ៊ុស្ហា មិនហ្វ៊ូ អ៊ីបាឌ្ហូកាស្ហ់-ស្ហ៍លីហ្វ៊ូន ។



**មេរៀនទី ១០**

# ស្ហ៊ីហ្វាត់ ស្ហ៊ូប៊ូទីយ៉ាស្ហ់ (الصفات الثبوتية)

គុណសម្បត្តិដែលសមសម្រាប់អល់ឡោះហ្វ៍នោះ ហៅថា "ស្ហ៊ីហ្វាត់ ស្ហ៊ូប៊ូទីយ៉ាស្ហ់" ។ មានច្រើនតែយើងលើកយកមកតែ ៨ ទេ គឺ៖

**១. ក្ហ៍ឌ្ហីម** (المقدم) មានន័យថា អល់ឡោះហ្វ៍អមតៈ ។ ព្រះអង្គមិនមានដើមកំណើត មិនមានទីបញ្ចប់ ។

**២. ក្ហ៍ឌ្ហៀរ** (القادر) មានន័យថាអល់ឡោះហ្វ៍មានសព្វានុភាព ។ ព្រះអង្គមានអំណាចលើអ្វីៗសព្វគ្រប់និងលើសព្វកិច្ចការ ។

**៣. អ៊ុលីម** (العليم) មានន័យថាអល់ឡោះហ្វ៍ទ្រង់ញាណសព្វគ្រប់ ។ ព្រះអង្គស្គាល់អ្វីៗសព្វគ្រប់ ។ មិនមានអ្វីមួយឬអ្នកណាមួយអាចលាក់បាំងពីព្រះអង្គបានឡើយ ។ ពុំមានអាចថិកំបាំងសម្រាប់ព្រះអង្គឡើយ ។

## មេរៀនទី ១១

# ម៉ាសាអ៊ីល យ៉្ជាប៊ីរ៉ោះត្ហ៍ (جَبِيرَة)

**អ្វី យ៉្ជាប៊ីរ៉ោះត្ហ៍ ?**

ការរុំ (ចងបន្ទះឈើ ឬ បូកម្នាងសិលា) លើរបួសឬឆ្អឹងបាក់ ឬការចតថ្នាំលើរបួសក៏ ហៅថា យ៉្ជាប៊ីរ៉ោះត្ហ៍ដែរ ។

ក្នុងនីតិសាស្ត្រអ៊ីស្លាម (គឺហ្វីក្ហោះហ្ហ៍អ៊ីស្លាម) យ៉្ជាប៊ីរ៉ោះត្ហ៍ គឺវត្ថុឬថ្នាំប្រើសម្រាប់រុំ (ប៉ង់សឺម៉ង់) ឬ ចង ។

វូឌុអ៍ អាល់-យ៉្ជាប៊ីរ៉ោះត្ហ៍ មានន័យថា វូឌុអ៍លើក្រណាត់ សំពត់រុំរបួស ឬលើព្រួលស្នប ដែលចងជាប់ប៉ែកមួយរបស់ រូបកាយដែលត្រូវយកទឹកវូឌុអ៍ ។

**យកទឹក វូឌុអ៍ អាល់-យ៉្ជាប៊ីរ៉ោះត្ហ៍ នៅពេលណា ?**

វូឌុអ៍ អាល់-យ៉្ជាប៊ីរ៉ោះត្ហ៍ ប្រើបានតែក្នុងករណីដូចតទៅគឺៈ



# ស៊ីហ្វាត់ សាល់ប៊ីយ៉ាស៊្ហ (الصفات السلبية)

គុណវិបត្តិដែលគេមិនឃើញមានលើអល់ឡោះហ្ហ៍ ។ មាន ច្រើនផងដែរ តែយើងលើកយកមកតែ ៨ ទេ គឺៈ

**១. ស្ហ៊ារីក** (شرك) ពាក្យថា "ស្ហ៊ារីក" មានន័យថា ដៃគូ អ្នកមានវិជ្ជាជីវៈដូច ឬ សហការី ។ អល់ឡោះហ្ហ៍មិនមាន សហការីឬដៃគូទេ ។

**២. មូរ៉ក់កាប់** (مركب) មានន័យថា ល្បាយចម្រុះ ឬ លាយ ។ អល់ឡោះហ្ហ៍មិនកើតមកពីអ្វីទេ ។ មិនអាចបែងចែកព្រះអង្គបានឡើយ ទោះបីក្នុងសេចក្តីស្រមៃក៏ដោយ ។

**៣. ម៉ាកាអាន់** (مكان) មានន័យថា កន្លែង ។ អល់ឡោះហ្ហ៍មិន មានទីកន្លែងជាស្ថាពរទេ មិនមានខ្លួនប្រាណទេ ។ ព្រះអង្គ ទ្រង់គង់នៅសព្វទីកន្លែង ។

**៤. ហ៊ូលុល** (حلول) មានន័យថា ចូល ។ មិនមានអ្វីមួយអាច ចូលក្នុងអល់ឡោះហ្ហ៍បានឡើយ ។ ព្រះអង្គមិនចូលក្នុងរូប

កាយនិងវត្ថុទេ ។ ឧទាហរណ៍ ពួកគ្រិស្តគិតថាយេស៊ូ រស់ឡើងវិញទៅជាវិញ្ញាណរបស់ព្រះ ។

**៥. ម៉ាហ្កាលី ហ្កាវ៉ាឌីស្ង** មានន័យថា រមែងតែផ្លាស់ប្តូរ ។ អល់ឡោះហ្វ៍មិនផ្លាស់ប្តូរតាមពេលវេលាទេ ។

**៦. ម៉ារអ៊ី** (مرئي) មានន័យថា អាចមើលឃើញ ។ គេមិនដែលមើលឃើញព្រះអង្គឡើយ ហើយនឹងមិនឃើញព្រះអង្គឡើយ ព្រោះព្រះអង្គមិនមានខ្លួនទេ ។

**៧. អ៊ិះហ្ទ៍ទីយ៉ាច់** មានន័យថា នៅក្នុងចំណុះគេ ឬ ត្រូវការ ។ អល់ឡោះហ្វ៍មិននៅក្នុងចំណុះអ្នកណាឡើយ ហើយក៏មិនត្រូវការអ្នកណាឡើយ ។

**៨. ស៊ីហ្វាត់ ស្ញអ៊ីដ្ទ** (صفت زائد) មានន័យថា គុណសម្បត្តិដែលរកបាន ។ គុណសម្បត្តិអល់ឡោះហ្វ៍មិនអាចញែកចេញបានពីព្រះអង្គឡើយ ។ ឧទាហរណ៍ យើងថាអល់ឡោះហ្វ៍ជាអ៊ាលីម មិនមានន័យថាការចេះដឹងរបស់ព្រះអង្គបែកផ្សេងពីព្រះអង្គនោះទេ ។ មិនដែលមានពេលណាមួយដែលព្រះអង្គមានការចេះដឹង តិចជាងពេលណាមួយ



ទៀតឡើយ ។

មានគ្រោះថ្នាក់ ចូរឲ្យយកទឹកវូឌុអ៏តាមរបៀបដែលទឹកអាចជ្រាបដល់ទៅមុខរបួសបាន ។

៦. ពេលណាមិនងាយយកក្រណាត់រុំចេញបានទេ ហើយមុខរបួសក្នុងក្រណាត់រុំនោះណាយ៉ឺស មុនយកទឹកវូឌុអ៏ ត្រូវធ្វើឲ្យវាទាំងពីរនេះបរិសុទ្ធស្អាតសិន ។ តែក្នុងករណីដែលមិនអាចធ្វើទៅបានទេ ឬមានគ្រោះថ្នាក់ពេលសម្អាតឲ្យបរិសុទ្ធនោះ ត្រូវធ្វើតាយ៉ាំមុម ។

៧. បើមុខនិងដៃមួយឬដៃទាំងពីរត្រូវរុំជិតអស់តែម្តង ត្រូវធ្វើតាយ៉ាំមុមបន្ទាប់មកត្រូវយកទឹកវូឌុអ៏លើក្រណាត់រុំ ។

៨. សំលៀកបំពាក់ស្វ៍ឡាត់ មិនត្រូវធ្វើអំពីស្បែកសត្វហារ៉ាំទេ ឬធ្វើអំពីសូត្រទេ (សម្រាប់បុរស) ។ តែមិនខុសទេបើក្រណាត់រុំនោះធ្វើអំពីវត្ថុទាំងនេះ ។

៩. បើមានក្រណាត់រុំលើបាតដៃនិងលើម្រាមដៃ ហើយបើដៃទទឹកជូតលើក្រណាត់រុំ នោះក្នុងពេលយកទឹកវូឌុអ៏ ពេលជូត (ម៉ាសាស៊ុ) ក្បាលឬជូតជើង ត្រូវប្រព្រឹត្តទៅជាមួយទឹកតែមួយនេះដែលទទឹកក្រណាត់រុំដៃនេះ ។ នៅលើប៉ែកដែលត្រូវយកទឹកវូឌុអ៏នោះ បើមានអ្វីផ្សេងពីថ្នាំដែលពិបាកយក



១. បើក្រណាត់រុំរបួសដែលមានស្បែកមុតឬរលាត់ កុំឲ្យតែក្រណាត់នោះរុំជិតទាំងស្រុងប៉ែកដែលត្រូវយកទឹកវូឌុអ៏ ។

២. ពេលមានព្រួលស្ងួបអមអវយវៈណាមួយ កុំឲ្យតែក្រណាត់នោះរុំជិតទាំងស្រុង ប៉ែកដែលត្រូវយកទឹកវូឌុអ៏ ។

**វូឌុអ៏ អាល់-យ៉ាប៊ីរ៉ោះត៏**

| | |
|---|---|
| រុំលើស្បែកមុតឬរលាត់<br>+<br>មិនត្រូវរុំជិតទាំងស្រុងប៉ែកដែលត្រូវយកទឹកវូឌុអ៏នោះទេ ។ | ព្រួលស្ងួបអមឆ្អឹងបាក់<br>+<br>មិនត្រូវរុំជិតទាំងស្រុងប៉ែកដែលត្រូវយកទឹកវូឌុអ៏នោះទេ ។ |

**សំណួរ**

តើត្រូវយកទឹកវូឌុអ៏របៀបណា បើក្រណាត់រុំឬព្រួលស្ងួបគ្របជិតប៉ែកដែលត្រូវយកទឹកវូឌុអ៏ ?

ក្នុងករណីនេះ

| | |
|---|---|
| បើប៉ែកដែលត្រូវរុំជិតនោះជាជើងមួយ ឬជើងទាំងពីរ ឲ្យធ្វើតាយ៉ាំមុម | បើប៉ែកដែលត្រូវរុំជិតនោះជាខ្នងដៃ ឬ មុខ ឲ្យយកទឹកវូឌូអ៊ុ អាល់-យ៉ាប៊ីរ៉េាះត៍ |

បើអាចលាងរបួសដោយយកក្រណាត់រុំចេញបាន ចាំបាច់ត្រូវយកទឹកវូឌូអ៊ុធម្មតា ។ បើមិនអាចយកក្រណាត់រុំចេញបានទេ ឲ្យយកដៃជូតលើក្រណាត់រុំទាំងស្រុង ។

ប្រសិនបើក្រណាត់នោះរុំលើរបួសស្រាល ឬគ្រាន់តែជាការតែងលំអទេ ចាំបាច់ត្រូវយកទឹកវូឌូអ៊ុធម្មតា បើធ្វើទៅបាន ។ ពុំនោះទេ ឲ្យធ្វើតាយ៉ាំមុម ។

**យ៉ាប៊ីរ៉េាះត៍ - ពេលណាធ្វើតាយ៉ាំមុម ពេលណាយកទឹកវូឌូអ៊ុ**

១. បើមានរបួសបើកមុខ ឬបាក់ឆ្អឹង ត្រង់ប៉ែកដែលត្រូវយកទឹកវូឌូអ៊ុនោះ (ប៉ែករូបកាយដែលគេយកទឹកវូឌូអ៊ុ រាប់បញ្ចូលការជូតម៉ាសាស៊ុដែរ ក្បាលនិងជើង) បើទឹកមិនធ្វើឲ្យមានគ្រោះថ្នាក់ទេ ចាំបាច់ត្រូវយកទឹកវូឌូអ៊ុធម្មតា ។



២. បើមានរបួសបើកមុខ ឬបាក់ឆ្អឹង លើដៃ ហើយបើទឹកធ្វើឲ្យមានគ្រោះថ្នាក់ ត្រូវលាងប៉ែកជុំវិញរបួសពីលើមកក្រោម យកល្អឲ្យយកដៃទទឹកជូតលើកន្លែងរបួស (ដូចគេម៉ាសាស៊ុដែរ) បើមិនធ្វើឲ្យមានគ្រោះថ្នាក់ទេ ។ បន្ទាប់មកយកក្រណាត់ បរិសុទ្ធរុំលើមុខរបួសហើយយកដៃទទឹកជូតលើក្រណាត់ម្តងទៀត ។

៣. បើមានរបួសបើកមុខ ឬបាក់ឆ្អឹង លើក្បាលប៉ែកខាងមុខ ឬ លើជើង ដែលមិនអាចម៉ាសាស៊ុ (គឺជូត) បានទេ ចាំបាច់ត្រូវធ្វើតាយ៉ាំមុមមុន បន្ទាប់មកយកទឹកវូឌូអ៊ុ អាល់-យ៉ាប៊ីរ៉េាះត៍ ។ ត្រូវរុំមុខរបួសដោយក្រណាត់បរិសុទ្ធ ហើយម៉ាសាស៊ុ (គឺជូត) ពីលើ ។

៤. បើមុខរបួសត្រូវរុំពីលើ ហើយអាចត្រូវទឹកបានដោយមិនធ្វើឲ្យមានគ្រោះថ្នាក់ទេ ត្រូវយកវត្ថុរុំចេញ ហើយយកទឹកវូឌូអ៊ុធម្មតា ។

៥. បើមិនអាចយកក្រណាត់រុំចេញពីមុខរបួសបានទេ ហើយក្រណាត់រុំនិងមុខរបួសនោះស្អាត ហើយបើទឹកអាចទៅដល់មុខរបួសបាន (ដោយជ្រាបតាមក្រណាត់រុំ) ដោយមិនធ្វើឲ្យ

គឺវ៉ាយ៊ីបដែលទៅជាចាំបាច់ ដោយសារតែវ៉ាយ៊ីបមួយទៀត ។ ឧទាហរណ៍ អ្នកសម្រេចចិតទៅបំពេញពិធីហ្ជាច្ចមុនបានទៅជា "មុសតាត់អ៊ី" អ្នកចាំបាច់ត្រូវបង់ប្រាក់ឃុមស៍ឲ្យរួចសព្វគ្រប់សិនដែលជាវ៉ាយ៊ីបមួយផងដែរ ។

**៤. វ៉ាយ៊ីប តាយ៊ីរី**

គឺវ៉ាយ៊ីបតាមជម្រើស ។ ឧទាហរណ៍ ក្នុងរ៉ក់អ្ញុត់ទី ៣ និង ទី ៤ របស់ស្វឡាត់ ប្រចាំថ្ងៃ វ៉ាយ៊ីបឲ្យសូត្រស្វរ៉េាះត៍ "អាល់-ហ្វាំង៍" ឬ "តាស់ប៊ីហ្វាត់ អារបាអ្ញុស៍"។ អ្នកអាចជ្រើសរើសយកមួយណាក៏បាន តែមិនអាចចោលទាំងពីរបានទេ ។

**៥. វ៉ាយ៊ីប គីហ្វាអ៊ី**

គឺវ៉ាយ៊ីបចាំបាច់លើទាំងអស់គ្នា តែបើមានអ្នកណាម្នាក់បានបំពេញវ៉ាយ៊ីបនេះត្រឹមត្រូវហើយ អ្នកឯទៀតមិនបាច់ធ្វើទេ ។ ឧទាហរណ៍ មានមនុស្សមួយក្រុមនៅក្នុងសាលបុគ្គលណាម្នាក់បានចូលមកដោយថា "អាស់សាឡាមូអ្ញាឡៃគុម"។ ទាំងអស់គ្នាចាំបាច់ត្រូវឆ្លើយតបវិញ ទាល់តែមានអ្នកណាម្នាក់ឆ្លើយតបវិញថា "អាឡៃគុម សាឡាម"។



ចេញ ឧទាហរណ៍ថ្នាំលាបជាដើម ត្រូវធ្វើតាយ៉ាំមុម ។

១០. ស្រដៀងវូឌូអ៍ដែរ ច្បាប់ពាក់ព័ន្ធនឹងក្រណាត់រុំប្រើសម្រាប់គុសល៍ដែរ ។ ក្នុងករណីនេះ អនុញ្ញាតចំពោះតែគុសល៍ តារទីប៊ី ទេ (មិនអាចប្រើ គុសល៍ អៀរទីម៉ាសី (الارتماسى) បានទេ ។

១១. ក្នុងករណីដែលមានរបួសលើប៉ែកណាមួយ នៃរូបកាយហើយចាំបាច់ត្រូវងូតទឹកគុសល៍ ឲ្យជ្រើសរើសយកតាយ៉ាំមុម ឬ យកគុសល៍ ដោយអនុវត្តិតាមច្បាប់យ៉ាប៊ីរ៉េាះត៍ ។

១២. ប្រសិនបើអ្នកណាមិនប្រាកដថាត្រូវយកទឹកវូឌូអ៍ ឬត្រូវធ្វើតាយ៉ាំមុម ឲ្យអ្នកនោះធ្វើទាំងពីរ ។

**មេរៀនទី ១២**

# ពាក្យបច្ចេកទេសអ៊ីស្លាម

**១. យ៉ាហ្វ៊ស់រីយ៉ាស់ និង អ៊ិះខ័ហ្វាទីយ៉ាស់** (صلاة جهرية صلاة اخفاتية)

ច្បាប់យ៉ាហ្វ៊ស់រីយ៉ាស់និងអ៊ិះខ័ហ្វាទីយ៉ាស់ ប្រតិបត្តិលើស្វ៏ឡាត់ប្រចាំថ្ងៃទាំង ១៧ រ៉ក់អ៊ាត់ ។

សម្រាប់បុរស ៖

ស្វ៏ឡាត់ ហ្វាច្ង៉ រ៍ ម៉ាក់រីប និង អ៊ីស្ហាអ៍ ជាប្រភេទស្វ៏ឡាត់យ៉ាហ្វ៊ស់រីយ៉ាស់ ពោលគឺ ត្រូវសូត្រស្វ៏ឡាត់ទាំងនេះដោយប្រើសម្លេងខ្លាំង ដូចយ៉ាងបើមានអ្នកណានៅក្នុងបន្ទប់ស្វ៏ឡាត់ អ្នកអាចឮគេសូត្រ ។ ក៏ប៉ុន្តែត្រូវសូត្រ តាស់បីហ្វាត់ អារបាអ៊ាស់ ដោយប្រើសម្លេងខ្សោយ ។

ស្វ៏ឡាត់ ស្ហ៊ុស្វរ៍ និង អ៊ាស្ង៉រ៍ អនុវត្តិតាមច្បាប់អ៊ិះខ័ហ្វាទីយ៉ាស់ ពោលគឺ ត្រូវសូត្រ គ្មីរ៉អ៊ាត់ និង



តាស់បីហ្វាត់ អារបាអ៊ាស់ ដោយប្រើសម្លេងខ្សោយ ។ ក៏ប៉ុន្តែអាចសូត្រស៊ីករ៉ងទៀតដោយប្រើសម្លេងខ្លាំងបាន ។

សម្រាប់ស្រ្តី ៖

ស្វ៏ឡាត់ ហ្វាច្ង៉ រ៍ ម៉ាក់រីប និង អ៊ីស្ហាអ៍ ជាប្រភេទស្វ៏ឡាត់យ៉ាហ្វ៊ស់រីយ៉ាស់ ពោលគឺ ត្រូវសូត្រស្វ៏ឡាត់ទាំងនេះដោយប្រើសម្លេងខ្លាំង លើកលែងតែ តាស់បីហ្វាត់ អារបាអ៊ាស់ ។

ស្វ៏ឡាត់ ស្ហ៊ុស្វរ៍ និង អ៊ាស្ង៉រ៍ ជាប្រភេទស្វ៏ឡាត់អ៊ិះខ័ហ្វាទីយ៉ាស់ ពោលគឺ មិនត្រូវសូត្រដោយប្រើសម្លេងខ្លាំងទេ ។

**២. វ៉ាយ្ហ៊ីប អាល់-អ៊ៃនី**

គឺវ៉ាយ្ហ៊ីបដែលចាំបាច់លើបុគ្គលគ្រប់រូប ។ ឧទាហរណ៍ ស្វ៏ឡាត់ ។

**៣. វ៉ាយ្ហ៊ីប អាល់-ហ្វៅរី**

ដាច់ត្ថ៌ហ្វារ៉ត្ទ៉ទេដោយសារអ៊ីសទីបរ៉អ៊្ម័របស់អ្នក ។

ប្រសិនបើអ្នកមិនបានធ្វើអ៊ីសទីបរ៉អ៊្ម័ទេ អ្នកត្រូវតែសន្មតថាទឹកនោះជាទឹកនោម អ្នកត្រូវធ្វើឲ្យខ្លួនអ្នកបរិសុទ្ធ ។



ឧទាហរណ៍មួយទៀតគឺ គ្ញុសល៍ កាហ្វាន់ និង ស្វ៌ឡាត្ទ៉ម៉ាឃិត ។ ជាវ៉ាយ៉្មីបលើទាំងអស់គ្នា បើមានអ្នកណាម្នាក់ស្ម័គ្រចិត្តធ្វើកាតព្វកិច្ចនេះ អ្នកឯទៀតមិនបាច់ធ្វើទេ ។ ក្នុងករណីនេះ យកល្អឲ្យអ្នកស្ម័គ្រចិត្តបញ្ជាក់ក្នុងនៀតថា "វ៉ាយ៉្មីប គីហ្វាអ៊ី" ។

**មេរៀនទី ១៣**

# អាស៊ុំកាមុល អ៊ីសទីបរ៉អ៊ុំ

## អ្វី អ៊ីសទីបរ៉អ៊ុំ?

អ៊ីសទីបរ៉អ៊ុំគឺទង្វើសូណាត់សម្រាប់បុរស ក្រោយពីបត់ជើងតូច ។ ដើម្បីធានាថាទឹកនោមមិនមានសល់នៅក្នុងអង្គជាតទេ ។ ចូររំលឹកថាទឹកនោមជាណាយុីស បើមិនជម្រះឲ្យត្រឹមត្រូវទេ ខ្លួននិងសំលៀកបំពាក់អាចទៅជាណាយុីសដែរ ទង្វើ (អាុម៉ាល់) ទាំងឡាយដូចជាស្វ៍ឡាត់ ជាដើម នឹងមោឃៈក្នុងពេលមានណាយុីសនេះ ។ សូមរំលឹកឡើងវិញថាអ៊ីស្លាមដាក់មកជាវ៉ាយុីបនូវបីពេលស្វ៍ឡាត់ (គឺ ៥ ស្វ៍ឡាត់) ក្នុងមួយថ្ងៃ ។ ដូច្នេះអ្នកចាំបាច់ត្រូវរក្សាខ្លួនឲ្យស្អាតឲ្យបានញឹកញយ តាមដែលអាចធ្វើទៅបានក្នុងមួយថ្ងៃ ។

## របៀបអ៊ីសទីបរ៉អ៊ុំ



ទង្វើខាងក្រោមនេះជាវិធីយកទឹកនោម ដែលនៅសល់ចេញ ។

១. ប្រសិនបើក្រោយពីបត់ជើងតូចរួច គូថ (ទ្វារឧច្ចរៈ) ទៅជាណាយុីសដែរ ដំបូងត្រូវធ្វើឲ្យបរិសុទ្ធសិន ៣ ដង ។ ឬទាប់មក ត្រូវសង្កត់ ៣ ដង លើប៉ែកដែលនៅត្រង់ចន្លោះគូថនិងគល់អវយវៈនោម ដោយម្រាមដៃកណ្តាលរបស់ដៃឆ្វេង ។

២. បន្ទាប់មក ធ្វើចលនាមករកខាងចុងអវយវៈនោមដោយសង្កត់អវយវៈនោមដោយចង្អុលដៃនិងមេដៃរបស់ដៃឆ្វេង ។

៣. ចុងក្រោយ រលាស់ចុងអវយៈនោម ៣ ដង មុននឹងលាងវាដោយទឹក យ៉ាងហោចណាស់ ២ ទៅ ៣ ដង ។

## ផលប្រយោជន៍របស់អ៊ីសទីបរ៉អ៊ុំ

ប្រសិនបើក្រោយពីបានធ្វើអ៊ីសទីបរ៉អ៊ុំហើយ មានទឹកអ្វីមួយចេញមកទៀត ហើយគេមិនដឹងថាទឹកនោះជាទឹកនោម ឬមិនមែនទឹកនោមទេ អ្នកនៅតែបរិសុទ្ធដដែល ។ អ្នកមិន

ក. អ្នកចូលរួមក្នុងស្វ៍ឡាត់ម៉ាក់រីប ពេលដែលគេកំពុងតែឈរគ្នីយ៉ាមរ៉ក់អាត់ទី ២ (នេះជារ៉ក់អាត់ទី ១ សម្រាប់អ្នក) ។ ប៉ែកខាងឆ្វេងតារាងខាងក្រោមនេះ ជាទង្វើនិងការសូត្ររបស់អ៊ីម៉ាំ ។ ចូរសរសេរលើប៉ែកខាងស្តាំតារាងនូវទង្វើនិងការសូត្រដែលអ្នកនឹងធ្វើ ។

| រ៉ក់អាត់ទី ២ របស់អ៊ីម៉ាំ | រ៉ក់អាត់ទី ១ របស់អ្នក |
|---|---|
| | |
| ស៊ូរ៉ោះត៍ អាល់-ហ្វាំហ្វ | |
| គុនូត | |
| រូគុអ៍ | |
| សាច់ដ្ហាស់ | |
| តាស្ហាស់ហ្វ៊ូដ | |
| ងើបឡើងធ្វើរ៉ក់អាត់ទី ៣ | |
| | |
| **រ៉ក់អាត់ទី ៣ របស់អ៊ីម៉ាំ** | **រ៉ក់អាត់ទី ២ របស់អ្នក** |
| | |
| តាស់ប៊ីហ្វាត់ អារបាអាស់ | |
| រូគុអ៍ | |



## លំហាត់ ១

ក. ចូរគូសភ្ជាប់ជាមួយចម្លើយត្រឹមត្រូវ ។

| | |
|---|---|
| -ភាពស្មើគ្នាក្នុងសាសនាអ៊ីស្លាម | -ឧទាហរណ៍ លើសពី ១០ នាក់ក្នុងស្វ៍ឡាត់យ៉ាម៉ាអាស់ ។ |
| -ឯកភាព | -តម្រៀបជួរ រូគុអ៍ ចុះសាច់ដ្ហាស់ ។ល។ ក្រោយអ៊ីម៉ាំ ។ |
| -សេចក្តីស្រឡាញ់និងសហប្រតិបត្តិការ | -ម៉ាស់យ៊ីដយើងមានមនុស្សអ៊ូអរ ។ |
| -វិន័យ | -នៀតតែមួយ ភាសាតែមួយ ទង្វើដូចគ្នា ។ |
| -កិត្យានុភាពរបស់អ៊ីស្លាម | -អ្នកមាន អ្នកក្រ តូច ធំ ទាំងអស់គ្នាឈរទន្ទឹមស្មាគ្នា |
| -រង្វាន់ឥតព្រំដែន | -មនុស្សជួបជុំគ្នា បណ្តាលឲ្យកើតមាននូវមិត្តភាពនិងការរាប់អានគ្នាទៅវិញទៅមក ។ |

ខ. លំហាត់ដូចគ្នា

| | |
|---|---|
| -ម៉ាក់មុម | -អ្នកគ្រប់អាយុ ដឹងខុសត្រូវ ។ |
| -យ៉ាំម៉ាអុ្វស៍ | -អ្នកស្វ៍ឡាត្វ៍ពីក្រោយអ៊ីម៉ាំ ។ |
| -អ៊ីម៉ាំ | -អ្នកនាំមុខស្វ៍ឡាត្វ៍ ។ |
| -បាលីក៊ | -ប្រជុំ ។ |

## លំហាត់ ២

ក. ចូរសរសេរ "ខ" (ខ្លាំង) "ត" (តិចៗ) នៅលើតារាងសូត្រ របស់អ៊ីម៉ាំយ៉ាំម៉ាអុ្វស៍ ។

| សូត្រ | ស្ទុស្វរ៍ | ម៉ាក់រីប |
|---|---|---|
| | | |
| ស្វ៉េះត្វ៍ អាល់-ហ្វាំង៍ | | |
| ប៊ិសមិលឡាហ្វៀរ រ៉េះហ្វ៉ម៉ាន-នៀរ៉ហ្វ៊ីម | | |
| គ្នូត | | |
| តាស់ប៊ីហ្វាត់ អារបាអុ្វស៍ | | |



| | | |
|---|---|---|
| ស៊ីករ៍ រូគុអ៍ | | |
| ស៊ីករ៍ សាច់ដ្វាស់ | | |
| តាស្ហាស់ហ្វ៊ូដូ និង សាឡាម | | |
| ស្វ៉េះត្វ៍ទី ២ ក្រោយ អាល់-ហ្វាំង៍ | | |

ខ. តើអ្នកធ្វើដូចម្តេចក្នុងករណីនេះ គឺៈ

១. អ្នកទៅម៉ាស់យ៊ីដដើម្បីចូលរួមស្វ៍ឡាត្វ៍ស្ទុស្វរ៍ តែអ្នកមិនដឹងថាស្វ៍ឡាត្វ៍ដល់រ៉ក់អុ្វត្វ៍ណាហើយទេ ដែលកំពុងតែគ្វីយ៉ាមនោះ ?

២. អ្នកចូលរួមក្នុងស្វ៍ឡាត្វ៍យ៉ាំម៉ាអុ្វស៍ ក្នុងរ៉ក់អុ្វត្វ៍ទី ៣ ។ អ៊ីម៉ាំរូគុអ៍ ហើយងើបឡើងវិញ តែអ្នកសូត្រមិនទាន់ចប់ ស្វ៉េះត្វ៍ អាល់-ហ្វាំង៍ ទេ ?

៣. អ្នកចង់រូគុអ៍តាមអ៊ីម៉ាំ តែខ្លាចអ៊ីម៉ាំងើបឡើងវិញមុនអ្នកតាមទាន់ ?

## លំហាត់ ៣

៤. សាច់ជ្រូកជាណាយ៉ីសព្រមទាំងហ្វារ៉ាំផង ។ ក៏ប៉ុន្តែពេមវា ក្រចកវា ឆ្អឹងវា ធ្មេញវា បរិសុទ្ធទាំងអស់ ។ ការអះអាងនេះ...

ក) ខុស ខ) ត្រូវ គ) មិនត្រូវ មិនខុស

៥. វត្ថុណាយ៉ីសធ្វើឲ្យវត្ថុមួយទៀតទៅជាណាយ៉ីស ដោយការប៉ះពាល់ ប្រសិនបើ...

ក) វត្ថុណាមួយ ក្នុងចំណោមវត្ថុទាំងពីរនេះទទឹកឬសើម ។
ខ) វត្ថុណាមួយ ឬ វត្ថុទាំងពីរស្ងួត ។
គ) មិនមានវាក្យសម្ព័ន្ធណាមួយខាងលើនេះត្រឹមត្រូវទេ ។

៦. មួយណាមិនត្រូវនៅក្នុងចំណោមបីនេះគឺៈ

ក) ឆ្កែ
ខ) ជ្រូក
គ) គោ



| | |
|---|---|
| សាច់ដ្វាស្ញ៉ | |
| តាស្ហាស្ញ៉ហ្វ៊ដ្ឋ | |
| សាឡាម | |

ខ. បើស្វ៉ឡាត់យ៉ាម៉ាអ៊ុស្ញ៉ដំណើរការដល់តវិយាបថ ខាងក្រោមនេះ តើអ្នកអាចចូលរួមបានទេ ? ចូរឆ្លើយថា "បាន" ឬ "ទេ" ។

| | |
|---|---|
| គ្នូទូត | |
| គ្នីយ៉ាមក្រោយរ្វគុអ៊ុ | |
| ក្នុងចន្លោះសាច់ដ្វាស្ញ៉ទាំងពីរ | |
| គ្នីយ៉ាមរ៉ក់អ៊ុត្ញ៉ទី ១ | |
| សាឡាម | |
| សាច់ដ្វាស្ញ៉ចុងក្រោយបង្អស់ក្នុងរ៉ក់អ៊ុត្ញ៉ចុងក្រោយបង្អស់ | |
| តាស្ហាស្ញ៉ហ្វ៊ដ្ឋ | |

គ. ស្វ៉ឡាត់ណាខ្លះ ដែលអាចធ្វើជុំគ្នាបានជាយ៉ាម៉ាអ៊ុស្ញ៉ ? ចូរគូសជុំវិញចម្លើយត្រឹមត្រូវ ។

១) វ៉ាស្ទ់ស្ហាត្ទ់(الوحشة)
២) ស្ទ៊ុបហ៊្ហ៍
៣) អ៊ីដ្ទុខ្មែន៍
៤) យ៉ូមអ៊ាត្ទ់ (ថ្ងៃសុក្រ)
៥) ស្ទ៊ុស្ទរ៍
៦) ម៉ាក្ទុរីប
៧) ស្ទ៍ឡាត្ទ់ ម៉ាយិត
៨) អ៊ាស្ទ៉រ៍
៩) អ៊ីសទិសក្ទ៍អ៊ុ៍(الإستسقاء)

ឃ. អ្នកចង់ដឹកនាំស្ទ៍ឡាត្ទ់យ៉ាម៉ាអ៊ាស្ទ់ស្ទ៊ុស្ទរ៍

១) អ្នកត្រូវ_________________ _________________ _________________ _________________ គ្រប់វ័យអាចសូត្របានយ៉ាងត្រឹមត្រូវ ។

២) តើអ្នកអាចស្ទ៍ឡាត្ទ់ ពីក្រោយអ៊ីម៉ាំមុស្លីមស៊ុន្នីបានទេ ? ចូរអធិប្បាយចម្លើយរបស់អ្នក ។

## លំហាត់ ៤

ចូរឆ្លើយសំណួរដោយជ្រើសរើសយកចម្លើយត្រឹមត្រូវ និងដោយសរសេរតួអក្សរតំណាងចម្លើយ ។



១. ហ្វាដ្ទាស្ទ់(ធំ)ទាមទារទង្វើខាងក្រោមនេះ ដើម្បីធ្វើឲ្យបរិសុទ្ធវិញ គឺ៖

ក) នៀត + វូឌ្ទុអ៊ុ៍
ខ) នៀត + គ្ទុសល៍
គ) វូឌ្ទុអ៊ុ៍ + គ្ទុសល៍

២. ទឹកនោមនិងលាមករបស់សត្វមានជីវិត ខាងក្រោមនេះ ជាណាយ៉ីស គឺសត្វ៖

ក) ដែលឈាមបាញ់ ហើយសាច់របស់វាហ្វាឡាល់បរិភោគ ។
ខ) ដែលឈាមបាញ់ ។
គ) ដែលឈាមបាញ់ ហើយសាច់របស់វាហ្វារាំបរិភោគ ។

៣. វត្ថុទាំង ៣ ខាងក្រោមនេះ មួយណាទាមទារឲ្យមាននៀតដើម្បីធ្វើឲ្យបរិសុទ្ធ គឺ៖

ក) ស្រា ។
ខ) សាកសព ។
គ) ឈាម ។

ខ) បែរមុខទៅរគ្នីបឡាត់ជាទង្វើហាម៉ ។

គ) ចម្លើយទាំងពីរខាងលើនេះជាចម្លើយត្រឹមត្រូវ ។

## លំហាត់ ៧

១. តើឈាមសត្វមានជីវិតបរិសុទ្ធឬណាយ៉ីស ? ហេតុអ្វី ?

ក) មនុស្ស

ខ) ពស់

គ) បាពពៃ

២. ដៃអ្នកទទឹក អ្នកចាប់ដៃបុគ្គលកាហ្វៀរ (ជាការគំនាប់) តើដៃអ្នកទៅជាណាយ៉ីសទេ ? ហេតុអ្វី ?

៣. ចូរបំពេញក្រឡាតារាងខាងក្រោមនេះ ។ ប=បរិសុទ្ធ ណ=ណាយ៉ីស ក=ក្តៅ ត្រ=ត្រជាក់ ។

| ពេល | សាកសព (ប ឬ ណ) | អ្នកប៉ះសាកសព (ប ឬ ណ) | សាកសព (ក ឬ ត្រ) |
|---|---|---|---|



៧. ឈាមសត្វមួយរបស់សត្វខាងក្រោមនេះ មិនមែនណាយ៉ីស គឺៈ

ក) ពស់ ។

ខ) មនុស្ស ។

គ) ចៀម ។

៨. អ្វីដែលច្បាប់ស្ហារីអះស្ល៉ហៅថាមិនបរិសុទ្ធគឺៈ

ក) ត្រីហ្វៀរ ។

ខ) ណាយ៉ីស ។

គ) បរិសុទ្ធ ។

៩. ណាយ៉ាសាស្ល៉មានពីរប្រភេទ ពឹងផ្អែកលើករណីខាងក្រោមនេះ គឺៈ

ក) ដើមកំណើតរបស់ណាយ៉ាសាស្ល៉គឺមនុស្ស ឬ សត្វ ។

ខ) វិធីសម្រាប់ជម្រះឲ្យបរិសុទ្ធ ។

គ) ដើមកំណើតរបស់ណាយ៉ាសាស្ល៉ជាវត្ថុមានជីវិត ឬ គ្មានជីវិត ។

១០. សាកសពជាណាយ៉ីស (ច្រើនម៉ោងក្រោយពីបានស្លាប់) មុនគេងូតទឹកគុសល់-ម៉ាយិត ។ ក៏ប៉ុន្តែ តើប៉ែកណាខ្លះ ក្នុងចំណោមប៉ែកខាងក្រោមនេះ ដែលនៅតែបរិសុទ្ធដាច់ឡែកពីទឹក គុសល់-ម៉ាយិត ?

ក) សក់ និង ក្រចក ។
ខ) ធ្មេញ និង ឆ្អឹង ។
គ) ទាំងពីរខខាងលើនេះ ។

## លំហាត់ ៦

ចូរឆ្លើយសំណួរដោយជ្រើសរើសយកចម្លើយត្រឹមត្រូវ និងដោយសរសេរតួអក្សរតំណាងចម្លើយ ។

១. គុសល់មួយណាមិនមែនគុសល់វ៉ាយិប ?

ក) យ៉ូមអ៊ុត្តុំ ។
ខ) យ៉ាណាបាសុំ ។
គ) ណាស្ទ់រ៍(نذر) កសម៍(قسم) អាហ្វាដ្ទុំ(عهد) ។



២. ចំនួនគុសល់វ៉ាយិបមានៈ

ក) ៥
ខ) ៣
ឃ) ៧

៣. ទឹកសម្រាប់គុសល់ចាំបាច់ត្រូវៈ

ក) តុំហ្វៀរ មុតឡាកុំនិងមូបាសុំ ។
ខ) តុំហ្វៀរ មុតឡាកុំនិងកុស់ប៊ី ។
គ) តុំហ្វៀរ មុតឡាកុំនិងមូដហុំ ។

៤. របៀបធ្វើ គុសល់ អៀរទីម៉ាស៊ី គឺៈ

ក) តាមតំណាក់ការ និងតាមលំដាប់ ។
ខ) លាងខ្លួនទាំងអស់តែម្តង ។
គ) ងូតទឹកធម្មតា ។

៥. ពេលបន្ទោបង់...

ក) និយាយជាទង្វើម៉ាក់រុះហ្វ៍ ។

ក) មុតឡាក្ញ់ ។
ខ) បរិសុទ្ធ
គ) ម្ជូហ្វ៉ៃ
ឃ) ណាយ៉ីស

៥. វត្ថុខាងក្រោមនេះ (ដែលត្រូវណាយ៉ីស) មិនអាចជម្រះបន្សុទ្ធដោយពន្លឺថ្ងៃផ្ទាល់បានទេ គឺ៖

ក) ដើមឈើ ។
ខ) ដី ។
គ) សំលៀកបំពាក់ដាក់ហាល ។
ឃ) ជញ្ជាំង ។

៦. ឧទាហរណ៍ពាក់ព័ន្ធនឹងដំណើរការរបស់អ៊ិនគ្វីឡាប់ គឺ៖

ក) ដំបងត្រូវណាយ៉ីសដែលទៅជាផេះ ។
ខ) ស្រាដែលត្រូវចម្រាញ់ទៅជាទឹកខ្មេះ ។
គ) សាកសពឆ្កែទៅជាដី ។
ឃ) សាកសពឆ្កែទៅជាអំបិល ព្រោះវាស្លាប់នៅក្នុងស្រែ ឬអណ្តូងអំបិល ។



| | | | |
|---|---|---|---|
| សាកសពក្រោយពីស្លាប់ភ្លាមៗ | | | |
| សាកសពក្រោយពីស្លាប់យូរ (មិនទាន់ផ្ទុតទឹកគុសល់ ម៉ាឃិត) | | | |
| សាកសពក្រោយពីស្លាប់យូរ (ផ្ទុតទឹកគុសល់ ម៉ាឃិតហើយ) | | | |

៤. បើអ្នកប៉ះសាកសព (បន្ទាត់ទី២ ជួរបញ្ឈរទី២) វ៉ាយ៉ីបឲ្យអ្នកងូតទឹក គុសល់________ ។

៥. តើអ្នកត្រូវលាងជម្រះបែបណា ក្រោយពីបានបត់ជើងតូចរួចក្នុងបង្គន់ (បុរសត្រូវអធិប្បាយពន្យល់របៀបធ្វើអ៊ីសទីបរ៉ស៍ដែរ) ។

៦. អ៊ីសទីបរ៉ស៍មានអត្ថប្រយោជន៍អ្វីខ្លះ (សម្រាប់តែបុរសទេ) ?

## លំហាត់ ៨ និង ៩

ចូរឆ្លើយសំណួរដោយជ្រើសរើសយកចម្លើយត្រឹមត្រូវ និងដោយសរសេរតួអក្សរតំណាងចម្លើយ ។

១. ទឹកមួយណាជាទឹកមុតឡាក់ ?

ក) ទឹកហូរ ។
ខ) ទឹកអណ្តូង ។
គ) ទឹកភ្លៀង ។
ឃ) ចម្លើយទាំងបីខាងលើជាចម្លើយត្រឹមត្រូវ ។

២. ហៅថាអាងទឹក "គូរ" គឺត្រូវមានប៉ែកខាង ពោលគឺ បណ្តោយ ទទឹង និងកំពស់ មានប្រវែងយ៉ាងហោចណាស់ស្មើនឹង...

ក) ២៣ សង់ទីម៉ែត្រ (២ តឹក) ។
ខ) ៦៩ សង់ទីម៉ែត្រ (៦ តឹក) ។
គ) ៧៦ សង់ទីម៉ែត្រ (៧ តឹក) ។



ឃ) ចម្លើយទាំងបីខាងលើនេះជាចម្លើយត្រឹមត្រូវ ។

៣. ខ្លួនអ្នកត្រូវណាយ៉ើសទឹកនោម ។
ដើម្បីជម្រះបន្សុទ្ធអ្នកត្រូវលាងសម្អាតយ៉ាង ហោចណាស់...

ក) មួយដងជាមួយទឹកនឹង ដែលមានចំនួនលើសពីមួយ "គូរ" ឬ ពីរដងជាមួយទឹកនឹងដែលមានចំនួនតិចជាងមួយ "គូរ" ។
ខ) ពីរដងជាមួយទឹកនឹង ដែលមានចំនួនលើសពីមួយ "គូរ" ឬ មួយដងជាមួយទឹកនឹងដែលមានចំនួនតិចជាងមួយ "គូរ" ។

គ) មួយដងជាមួយទឹកនឹង ដែលមានចំនួនលើសពីមួយ "គូរ" ឬ ពីរដងជាមួយទឹកនឹងដែលមានចំនួនតិចជាងមួយ "គូរ" ។

ឃ) បីដងជាមួយទឹកនឹង ដែលមានចំនួនលើសពីមួយ "គូរ" ឬ បីដងជាមួយទឹកនឹងដែលមានចំនួនតិចជាងមួយ "គូរ" ។

៤. ទឹកដែលប្រែពណ៌ ប្រែរសជាតិ និងប្រែក្លិនជាទឹក...

ក) បីដង ។

ខ) ពីរដង ។

គ) មួយដង ។

ឃ) ច្រើនដងស្រេចតែអ្នក ។

១៤. សត្វហ្រាទ្បាល់ត្រូវសំទ្បែះ ស្របតាមច្បាប់ស្ហារីអ្ុស្ញ់ (شريعة) ។ បរិមាណឈាមវាជាធម្មតា ។ ឈាមដែលនៅសល់ក្នុងខ្លួនវាជា...

ក) ឈាមបរិសុទ្ធ ។

ខ) ឈាមណាយ៉ីស ។

គ) ឈាមគួរ ។

ឃ) ឈាមហ្រាំ ។

១៥. អ្នកឃើញសំលៀកបំពាក់របស់មុស្លីម ទៅជាណាយ៉ីស ។ ក្រោយមក អ្នកឃើញគាត់ពាក់សំលៀកបំពាក់ដដែលបំពេញស្ហ៍ទ្បាត្ញ់ ។ អ្នកអាចគិតថាគាត់បានជម្រះបន្សុទ្ធវាហើយ ដោយអាស្រ័យលើលក្ខខណ្ឌ គឺ៖

ក) គាត់ជាអ្នកគោរពច្បាប់ស្ហារីអ្ុស្ញ់យ៉ាងខ្ជាប់ខ្ជួន ។



៧. តើអ៊ីសទីហ្រាទ្បាស្ញ់ (إستحالة) និងអ៊ីនគ្ជីទ្បាប់ខុសគ្នាត្រង់ណា ?

ក) សម្រាប់អ៊ីសទីហ្រាទ្បាស្ញ់ សណ្ឋាននិងទិដ្ឋភាពផ្លាស់ប្តូរ ។ ឯអ៊ីនគ្ជីទ្បាប់វិញ គុណភាពផ្លាស់ប្តូរ ។

ខ) សម្រាប់អ៊ីនគ្ជីទ្បាប់ សណ្ឋាននិងទិដ្ឋភាពផ្លាស់ប្តូរ ។ ឯអ៊ីសទីហ្រាទ្បាស្ញ់វិញ គុណភាពផ្លាស់ប្តូរ ។

គ) សម្រាប់អ៊ីសទីហ្រាទ្បាស្ញ់ គឺពាក់ព័ន្ធនឹងវត្ថុត្រូវណាយ៉ីស ។ ឯអ៊ីនគ្ជីទ្បាប់វិញ គឺពាក់ព័ន្ធនឹងសត្វមានជីវិត ។

ឃ) មិនខុសគ្នាទេ ។

៨. ពេលមូសបឺតឈាមអ្នក អ្នកវាយវាស្លាប់ (ឈាមប្រទ្បាក់ដៃអ្នក) ។ ឈាមនេះបរិសុទ្ធបើមានលក្ខខណ្ឌដូចតទៅគឺ៖

ក) អ្នកនៅស្រុកអាហ្វ្រិក ។

ខ) មានរយៈពេលមួយដែលឈាមនោះក្លាយ ទៅជា

ឈាមរបស់មូស ។

គ) អ្នកអាចមានជម្ងឺដោយសារមូសនោះខាំ ។

ឃ) ឈាមតិច ។

៩. បុគ្គលមិនមែនមុស្លីមទៅជាមុស្លីម ពេលបុគ្គលនោះ...

ក) ចាប់ផ្តើមបំពេញស្វ៍ឡាត្ធប្រចាំថ្ងៃទាំង ៥ ។

ខ) មានសទ្ធាចំពោះអល់ឡោះហ្វ៍តែមួយគត់ និងជឿព្រះសាស្តាទាំងឡាយ ។

គ) សូត្រកាលីម៉ាស្វ៍ដោយសទ្ធាស្មោះ ។

ឃ) វាក្យសម្ពន្ធ ខ) និង គ) ជាចម្លើយត្រឹមត្រូវ ។

១០. ពេលបុគ្គលមិនមែនមុស្លីមទៅជាមុស្លីម ក្នុងចំណោមអ្នកខាងក្រោមនេះ តើអ្នកណាទៅជាមុស្លីមដោយស្វ័យប្រវត្ត ?

ក) កូនៗរបស់បុគ្គលនោះដែលបាលិក្ក (គឺគ្រប់អាយុ) ។

ខ) ឪពុកម្តាយរបស់បុគ្គលនោះ ។

គ) កូនៗរបស់បុគ្គលនោះដែលមិនទាន់បាលិក្ក (គឺមិនទាន់គ្រប់អាយុ) ។

ឃ) បងប្អូនប្រុសស្រីរបស់បុគ្គលនោះ ។



១១. ពេលអណ្តូងទឹកត្រូវណាយ៉ីស គេធ្វើឲ្យវាទៅជាបរិសុទ្ធដោយយោងទឹកចេញមួយចំនួន ជញ្ជាំងអណ្តូងទឹកនេះ ខ្សែវានិងធុងដែលគេប្រើសម្រាប់ដួសទឹកទៅជាបរិសុទ្ធដែរ ជាស្វ័យប្រវត្ត ។ នេះគឺឧទាហរណ៍មួយរបស់...

ក) ស្វាវ៉ាល់ អាល់-អ៊ែន៍

ខ) អ៊ីសទីបរ៉អ៍

គ) តាបាអ៊ីយ៉ាស្វ៍

ឃ) អ៊ីសទីហ្វាឡាស្វ៍

១២. ប្រសិនបើមានឈាមក្នុងមាត់ ឬ លើច្រមុះ មាត់និងច្រមុះនឹងស្អាតដោយ...

ក) លាងជាមួយទឹកពីរដង ។

ខ) លាងជាមួយទឹកបីដង ។

គ) លាងជាមួយទឹកតែមួយដង ។

ឃ) យកឈាមចេញ ។ មិនបាច់លាងទេ ។

១៣. ចានត្រូវណាយ៉ីសស្រា អ្នកត្រូវលាងសម្អាតវាជាមួយទឹកតិចជាងមួយគូរ ឬ ជាមួយទឹកលើសពីមួយគូរ...

គ) តើគេបំពេញស្វ៍ឡាត់ឃ្ជុមអ៊ុត់បែបណា ?

កំណែលើកទី ២, 07/2020



ខ) គាត់បានអវត្តមានយូរគ្រាន់បើ ដើម្បីមានពេលជម្រះបន្សុទ្ធសំលៀកបំពាក់នោះ ។

គ) វាក្យសម្ពន្ធ ក) និង ខ) ជាចម្លើយត្រឹមត្រូវ ។

ឃ) អ្នកឃើញគាត់សម្អាតសំលៀកបំពាក់គាត់ ។

## លំហាត់ ១០

ព្រះសាស្តាមូហាំម៉ាដ់ﷺយើងមានព្រះវចនៈថាថ្ងៃសុក្រ ជាថ្ងៃល្អលើសថ្ងៃទាំងអស់នៃសប្តាហ៍ ។ ធ្វើទង្វើល្អមួយក្នុងថ្ងៃនេះបានរង្វាន់ច្រើន ។ គេនឹងទទួលយកស្វ៍ឡាត់ភ្លាមៗក្នុងថ្ងៃនេះ ។ ថ្ងៃសុក្រពិតជាថ្ងៃរបស់មុស្លីម ។ ពរជ័យសិរីសួស្តីដែលយើងអាចទទួលបានក្នុងថ្ងៃនេះ មានច្រើនអនេក ។ អល់ឡោះហ្វ៍عزّ وجلّបានចាត់ទុកនគរម៉ាក់កាស់ ជាកន្លែលមួយដែលពិសេសពិសាលដាច់អស់កន្លែងឯទៀតក្នុងលោក ព្រះអង្គعزّ وجلّបានចាត់ទុកខែរ៉ម៉ាដូនប្រសើរ ដាច់អស់ខែឯទៀត ព្រះអង្គعزّ وجلّបានចាត់ទុកថ្ងៃសុក្រ ប្រសើរដាច់អស់ថ្ងៃឯទៀត ។

ក) ថ្ងៃនេះ ម៉ាក់ស៊ូមីន ៦ អង្គ ក្នុងចំណោមម៉ាក់ស៊ូមីនទាំង ១៤ អង្គعليهم السلامបានចាប់កំណើត ។ ចូរសរសេរព្រះនាម

ម៉ាក់ឃ្លូមីនទាំង ៦ អង្គនេះដែលបានចាប់កំណើតក្នុងថ្ងៃដ៏ឱឡារិកនេះ ?

ខ) តើគេហៅថាអ្វី ស៊ុយ៉ារ៉ត់ដែលគេសូត្រជាពិសេសក្នុងថ្ងៃសុក្រ (ក្រោយស្វ៊ឡាត់ថ្ងៃសុក្ររួច) ? ហេតុអ្វីយើងសូត្រស៊ុយ៉ារ៉ត់នេះថ្ងៃសុក្រ ? (យើង មុស្លីមស្និអុាស្ល់ រង់ចាំព្រឹត្តិការណ៍ធំមួយដែលនឹងកើតឡើងក្នុងថ្ងៃសុក្រ) ។

គ) តើគេហៅស្នានពិធី (គឺគុស្វូល គឺការងូតទឹកសម្អាតកាយ) ដែលគេធ្វើក្នុងថ្ងៃនេះថាអ្វី (គុសល៍អ្វី) ? តើស្នានពិធីនេះជាវាយ៉ីប ឬ ជាស្វូណាត់ ?

ឃ) ប្រទេសមុស្លីមភាគច្រើនចាត់ទុកថ្ងៃនេះ ជាថ្ងៃបុណ្យ (អ៊ីដ្វ) ។ ចូរលើកឡើងនូវទង្វើ ៣ ដែលយើងធ្វើក្នុងថ្ងៃបុណ្យ ហើយដែលយើងអាចធ្វើបានក្នុងថ្ងៃសុក្រដែរ (យើងអាចធ្វើទង្វើទាំងនេះបានក្នុងពេលផ្សេង តែគេផ្ដែផ្ដាំថាល្អបំផុតចូរធ្វើទង្វើទាំង ៣ នេះក្នុងថ្ងៃសុក្រ ឬថ្ងៃបុណ្យ (អ៊ីដ្វ)) ។

ង) ខាងក្រោមនេះគឺឈ្មោះចំនួន ១០ របស់ថ្ងៃសុក្រ ។ ចូរគូសឈ្មោះថ្ងៃសុក្រនៅខាងឆ្វេង ភ្ជាប់ទៅរកន័យត្រឹមត្រូវរបស់វានៅខាងស្ដាំ ។



| | |
|---|---|
| យ៉ៅមុល ម៉ៅលុដ្វ | ថ្ងៃធម៌ |
| យ៉ៅមុល ហ្វាស្វ៉ល៍ | ថ្ងៃទទួលស្វ៊ឡាត់ |
| យ៉ៅមុល បារកាត់ | ថ្ងៃកិត្តិយស |
| យ៉ៅមុល ព៉ោះហ៍ម៉ាស់ | ថ្ងៃសាកល្បង |
| យ៉ៅមុល អ៊ីយ៉្ហាប៊ុត | ថ្ងៃកំណើតព្រះសាស្ដាﷺ |
| យ៉ៅមុល អ៊ីដ្វ | ថ្ងៃសម្បូរ |
| យ៉ៅមុល អ៊ីសក៍ | ថ្ងៃមេត្តាប្រណី |
| យ៉ៅមុល កុស៊ុវ៉ាស់ | ថ្ងៃពរជ័យ |
| យ៉ៅមុល ការ៉ម៉ាត់ | ថ្ងៃអត់ឱន |
| យ៉ៅមុល ម៉ាស៊ីដ្វ | ថ្ងៃបុណ្យ |

## លំហាត់ ១១

ក) ចូរអានសម្រាយស្វរ៉ោះត៍ យ៉ូមអុាត់ (៦២) ក្នុងព្រះគម្ពីរគួរអាន ។ ចូរស្វែងរកអាយ៉ាស់ដែលស្ដីអំពីស្វ៊ឡាត់យ៉ូមអុាត់ក្នុងស្វរ៉ោះត៍នេះ ។

ខ) តើស្វ៊ឡាត់យ៉ូមអុាត់ ខុសពីស្វ៊ឡាត់ធម្មតាត្រង់ណាខ្លះ ? ចូរផ្ដល់នូវបីខសំអាង ។